ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

របាយការណ៍ប្រចាំឆ្នាំ ២០១៩

មាតិកា

១. អំពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

២-៤. សារលិខិតរបស់ឯកឧត្តមអគ្គនាយក

៥. ទិន្នន័យហិរញ្ញវត្ថុសង្ខេប

៦-១០. ព្រឹត្តិការណ៍នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

១១-២៤ អភិបាលកិច្ចសាជីវកម្ម

- ១១-១២ ការគ្រប់គ្រងហានិភ័យនិងការត្រួតពិនិត្យផ្ទៃក្នុង
- ១៣ រចនាសម្ព័ន្ធធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
- ១៤-២០ ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល
- ២១-២៤ ប្រវត្តិរូបសង្ខេបរបស់គណៈគ្រប់គ្រង

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019
និងរបាយការណ៍របស់សវនករឯករាជ្យ

- ១-៦ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- ៧-១១ របាយការណ៍របស់សវនករឯករាជ្យ
- ១២-១៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- ១៤ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
- ១៥-១៦ របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន
- ១៧-១៩ របាយការណ៍លំហូរទឹកប្រាក់
- ២០-១៣៦ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

អំពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។ ធ.អ.ជ.ក.ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាធនាគារពាណិជ្ជ និងមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។ ធ.អ.ជ.ក.ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ ធនាគារជាតិនៃកម្ពុជា។

ចក្ខុវិស័យ

ចក្ខុវិស័យនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម គឺជាស្ថាប័នហិរញ្ញវត្ថុឈានមុខ ដែលផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ នៅប្រទេសកម្ពុជា។

បេសកកម្ម

ធ.អ.ជ.ក. មានបេសកកម្មដូចតទៅ÷

- បំពេញតួនាទីជាធនាគារពាណិជ្ជផង និងជាធនាគារគោលនយោបាយផង
- ផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាក់ព័ន្ធ រួមមាន សេវាឥណទាន សេវាទូទាត់ និងសេវាទទួលប្រាក់បញ្ញើដល់អតិថិជនគោលដៅក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម និងសេដ្ឋកិច្ចជនបទ
- ផ្តល់ការគាំទ្រជាគោលនយោបាយលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស រួមមាន ការសម្របសម្រួល និងដោះស្រាយបញ្ហាក្នុងខ្សែច្រវាក់ផលិតកម្ម វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ តាមរយៈការស្វែងរកទីផ្សារ ការផ្តល់យោបល់ និងការកសាងសមត្ថភាពជាដើម
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យា និងភាពច្នៃប្រឌិត ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវា និងបង្កើនឧត្តមភាពប្រកួតប្រជែងរបស់អតិថិជនក្នុងទីផ្សារ
- សហការ និង/ ឬ ធ្វើសហជីវការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុជាតិ និងអន្តរជាតិ ក្នុងការផ្តល់ហិរញ្ញប្បទាន ឬ អនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ
- អនុវត្តគម្រោងហិរញ្ញប្បទាន ឬ គ្រប់គ្រងមូលនិធិផ្សេងទៀត ក្នុងក្របខណ្ឌនៃកិច្ចសហការ ជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- គ្រប់គ្រងកម្មវិធី ឬ គម្រោងអន្តរាគមន៍របស់រាជរដ្ឋាភិបាល
- កៀរគរទុន និងហិរញ្ញប្បទាន សម្រាប់ពង្រីកសកម្មភាពរបស់ ធ.អ.ជ.ក.
- ផ្តល់សេវាធនាគារផ្សេងទៀត ពាក់ព័ន្ធនឹងការគ្រប់គ្រង និងចាត់ចែងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ជូនអតិថិជនគោលដៅ ព្រមទាំងប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ និងការទទួលខុសត្រូវសង្គមនិងបរិស្ថាន
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក្នុងការបំពេញតួនាទីភារកិច្ចរបស់ ធ.អ.ជ.ក.ឱ្យមានប្រសិទ្ធភាព។

សារលិខិតរបស់ឯកឧត្តមអគ្គនាយក

ឯកឧត្តម កៅ ថាច
អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

“ដោយទទួលបានទំនុកចិត្តកាន់តែខ្លាំងពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.) បានទទួលដើមទុនបន្ថែម ពីរាជរដ្ឋាភិបាលចំនួន ៥០ (ហាសិប) លានដុល្លារអាមេរិក ដើម្បីប្រែក្លាយ “ធនាគារអភិវឌ្ឍន៍ជនបទ” ទៅជា “ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម” ដែលបំពេញមុខងារជាធនាគារពាណិជ្ជផង និងធនាគារបម្រើគោលនយោបាយផង ហើយអាចបំពេញនូវកង្វះខាតរវាងតម្រូវការ និងការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ”

ក្នុងឆ្នាំ២០១៩ កន្លងនេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម សម្រេចបាននូវសមិទ្ធិផលល្អគាប់ប្រសើរគួរឱ្យកត់សម្គាល់ ទាំងលទ្ធផលប្រតិបត្តិការអាជីវកម្ម និងលទ្ធផលហិរញ្ញវត្ថុ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.) សម្រេចបាននូវការប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ ជា “ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម” ដែលបំពេញមុខងារជាធនាគារពាណិជ្ជផង និងធនាគារបម្រើគោលនយោបាយផង និងទទួលដើមទុនបន្ថែមពី រាជរដ្ឋាភិបាល ចំនួន ៥០ (ហាសិប) លានដុល្លារអាមេរិក តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការបំពេញមុខងារជាធនាគារណិជ្ជផង និងធនាគារបម្រើគោលនយោបាយផង អាចឱ្យធ.អ.ជ.ក. ផ្តល់សេវាធនាគារពេញលេញប្រកបដោយប្រសិទ្ធភាព និងចីរភាព សំដៅគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីរួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ ធ.អ.ជ.ក. សម្រេចបាននូវឥណទាននិងបុរេប្រទានសរុបប្រមាណ ១៧៣ លានដុល្លារអាមេរិក ក្នុងនោះសម្ភៀតឥណទានគាំទ្រដល់វិស័យស្រូវ និងអង្ករ រួមទាំង ឃ្លាំងស្តុក

និងឡសម្ងួតស្រូវ ចំនួន ៧៦,៩១% អនុវិស័យ រួមមាន៖ កៅស៊ូ ម្រេច កាហ្វេ ដំឡូងមី អំពៅ ពោតចំនួន ១៤,០៧% និងមីក្រូហិរញ្ញវត្ថុ ការចិញ្ចឹមសត្វនិងផ្សេងៗចំនួន ៩,៥២%។ ទំហំអាជីវកម្មក៏បានឆ្លុះបញ្ចាំងនឹងភាពរឹងមាំនៃលទ្ធផលសម្រេចបានផ្នែកហិរញ្ញវត្ថុផងដែរ។ ធ.អ.ជ.ក. ទទួលបានកំណើនលើទ្រព្យសកម្មសរុបប្រមាណ២២% ប្រាក់ចំណេញសុទ្ធកើនប្រមាណ១៦០% ព្រមទាំងដើមទុនកើនប្រមាណ ១២១% ធៀបនឹងឆ្នាំ២០១៨។

ក្រៅពីការអនុវត្តទទួលបានសិមិទ្ធផល នៃប្រតិបត្តិការអាជីវកម្មគួរកត់សម្គាល់ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានប្រឹងប្រែងយ៉ាងសកម្ម ក្នុងឆន្ទៈយ៉ាងមុតមាំ ចូលរួមដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ ក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល តាមរយៈការអនុវត្តកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល រួមមាន៖ ការអនុវត្តគម្រោងឥណទានពិសេសរបស់រាជរដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពតម្លៃស្រូវ និងការអនុវត្តគម្រោងវិនិយោគរបស់រាជរដ្ឋាភិបាលលើមជ្ឈមណ្ឌលប្រមូលទិញស្រូវ។ ទន្ទឹមនឹងការអនុវត្តបានជោគជ័យលើគម្រោងស្តុក និងឡសម្ងួតស្រូវនៅទីតាំងខេត្តបាត់ដំបង កំពង់ធំ ព្រៃវែង និងតាកែវ ក្នុងទំហំទឹកប្រាក់សរុប**៤៥ (សែសិបប្រាំ) លានដុល្លារអាមេរិក** និងបានចូលរួមចំណែកបង្កើនសមត្ថភាពស្តុក និងកិនកែច្នៃស្រូវ និងអង្ករនៅក្នុងតំបន់ផលិតស្រូវសំខាន់ៗនៃប្រទេស ជាចម្បងបម្រើឱ្យការនាំចេញ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មបាននិងកំពុងអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Climate Resilient Rice Commercialization Sector Development Program) ក្រោមកម្ចីសម្បទានសរុបចំនួន**១០ ៥០០ ០០០ (ដប់លានហាសិបម៉ឺន) ដុល្លារអាមេរិក** ពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់គម្រោងសាងសង់ឃ្លាំងស្តុក និងឡសម្ងួតស្រូវនៅខេត្តគោលដៅចំនួន ០៣ រួមមាន៖ ខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង។ គម្រោងសាងសង់ឃ្លាំងស្តុក និងឡសម្ងួតស្រូវនេះនឹងបង្កើនលទ្ធភាពប្រមូលទិញស្រូវពីប្រជាកសិករនៅតំបន់ផលិតស្រូវសំខាន់ៗទាំងនេះបន្ថែមទៀត រួមចំណែកការនាំចេញអង្ករ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្រៅពីវិស័យស្រូវ និងអង្ករ ក្នុងគោលដៅជំរុញផលិតកម្មបន្លែរបស់ប្រជាកសិករ ធានាបាននូវសុខុមាលភាពដល់ប្រជាជនហូបបន្លែ ធានាបានទីផ្សារដល់កសិករផលិតបន្លែសុវត្ថិភាព និងជួយកាត់បន្ថយការនាំចូលបន្លែ ធ.អ.ជ.ក. បានសហការជាមួយផ្នែកឯកជន ដែលជាក្រុមហ៊ុនប្រមូលទិញបន្លែ បង្កើតបានជាផ្សារបន្លែសុវត្ថិភាព ដែលមានឈ្មោះថា“**ផ្សារបន្លែសុវត្ថិភាពខ្មែរ** ”។ តាមរយៈយន្តការនេះ ធ.អ.ជ.ក. ជាអ្នកផ្តល់ហិរញ្ញប្បទានក្នុងអត្រាការប្រាក់អនុគ្រោះដល់បណ្តាកសិករ សហគមន៍ដាំបន្លែ ព្រមទាំងដល់ក្រុម-ហ៊ុនប្រមូលទិញបន្លែផងដែរ។

ដំណើរឆ្ពោះទៅមុខ

ជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំបន្ទាប់ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម នឹងពង្រីកវិសាលភាពប្រតិបត្តិការរបស់ខ្លួន ឱ្យកាន់តែប្រសើរ តាមរយៈការបង្កើតសាខា និងការិយាល័យចល័តធនាគារបន្ថែម ក៏ដូចជាការអភិវឌ្ឍន៍ផលិតផល និងសេវាកម្មថ្មី និងបែបឌីជីថល ដើម្បីផ្តល់សេវាពេញលេញ រហ័ស ដល់អតិថិជន។ ជាមួយគ្នានេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មនឹងអនុវត្តគម្រោងពិសេសរបស់រាជរដ្ឋាភិបាល និងគម្រោងអភិវឌ្ឍន៍នានា ដែលឆ្លើយតបនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាប្រឈម ពាក់ព័ន្ធនឹងវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ និងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មានឆន្ទៈនិងក្ដីសង្ឃឹមយ៉ាងមុតមាំ ខ្លាំងក្លា ដើម្បីបំពេញនូវបេសកកម្មរបស់ខ្លួន ក្នុងគោលដៅអភិវឌ្ឍន៍វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ ក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងទស្សនៈសុទិដ្ឋិនិយមខ្ពស់ក្នុងការសម្រេចបានតាមទិសដៅការងារក្នុងឆ្នាំ២០២០ ជាប្រាកដ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងនូវការកោតសរសើរយ៉ាងស្មោះ និងអំណរគុណចំពោះក្រុមប្រឹក្សាភិបាលដែលតែងតែគាំទ្រនិង ផ្ដល់អនុសាសន៍ដឹកនាំកិច្ចដំណើរការរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងសូមអរគុណចំពោះនិយោជិត ធ.អ.ជ.ក. ទាំងអស់ដែលបានខិតខំបំពេញការងារអស់ពីកំលាំងកាយចិត្ត ព្រមទាំងអរគុណចំពោះអតិថិជននិងដៃគូអភិវឌ្ឍន៍នានា ដែលបានចូលរួមសហការជាមួយ ធ.អ.ជ.ក. លើកស្ទួយការអភិវឌ្ឍន៍វិស័យកសិកម្ម នៃប្រទេសកម្ពុជា។

ខ្ញុំសូមសម្ដែងនូវការគោរពនិងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **រាជរដ្ឋាភិបាលកម្ពុជា** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលតែងតែគាំទ្រនិងផ្ដល់ទំនុកចិត្តមក ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

កៅ ថាច

ទិន្នន័យហិរញ្ញវត្ថុសង្ខេប

ការគូសបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ	២០១៩ (ដុល្លារអាមេរិក)	២០១៨ (ដុល្លារអាមេរិក)	២០១៧ (ដុល្លារអាមេរិក)
ចំណូលដុល	11,258,799	9,391,151	6,587,783
ចំណូលប្រតិបត្តិការមុនសំវិធានធន	7,608,986	4,889,002	2,799,915
លទ្ធផលមុនបង់ពន្ធ	8,412,681	3,353,915	1,153,088
លទ្ធផលក្រោយបង់ពន្ធ	6,672,904	2,564,287	953,254
ចំណុចសំខាន់ៗក្នុងតារាងតុល្យការ (គិតជាដុល្លារអាមេរិក)			
ទ្រព្យសកម្មសរុប	218,380,542	178,281,305	157,535,361
ដើមទុន	98,977,301	44,586,597	41,759,172
ឥណទាន និងបុរេប្រទាន	173,162,427	159,115,208	122,070,986
អនុបាតហិរញ្ញវត្ថុ (គិតជា%)			
ផលចំណេញលើដើមទុន	6.74	5.75	2.28
ផលចំណេញលើទ្រព្យសកម្ម	3.06	1.44	0.61
ឥណទានមិនដំណើរការធៀបនឹងឥណទានសរុប	7.25	3.58	3.16
អនុបាតសោធនភាព	47.61	28.41	34.10

ព្រឹត្តិការណ៍នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

កិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើទិដ្ឋភាពផ្នែកច្បាប់អំពីវិធានការដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រឈមលើទីផ្សារបន្លែសុវត្ថិភាព

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ នៅព្រឹកថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរៀបចំកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់ លើទិដ្ឋភាពផ្នែកច្បាប់អំពីវិធានការដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រឈមលើទីផ្សារបន្លែសុវត្ថិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ងួន សុខា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តម** រស់ សីលវ៉ា រដ្ឋលេខាធិការ និងជាប្រធានក្រុមប្រឹក្សាភិបាលធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម **ឯកឧត្តម** កៅ ថាចអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងមានការអញ្ជើញចូលរួមផងដែរ ពីខាងតំណាងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និង មន្ត្រីជំនាញរបស់ធនាគារអភិវឌ្ឍន៍បទ និងកសិកម្មផងដែរ។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ៣ភាគី ក្រោមកម្ចីសម្បទាន និងជំនួយឥតសំណងពី ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់គម្រោងសាងសង់និងប្រតិបត្តិ-ការឃ្លាំងស្តុក និងឡសម្ងួតស្រូវ

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ÷ នាព្រឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម វស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជានាយកកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Climate Resilient Rice Commercialization Sector Development Program) ឯកឧត្តម កៅ ថាច អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ៣ ភាគី (អង្គភាពអនុវត្តគម្រោងនៃកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងរោងម៉ាស៊ីនកិនស្រូវដែលបានជ្រើសរើស) ក្រោមកម្ចីសម្បទាន និងជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់គម្រោងសាងសង់ និងប្រតិបត្តិការឃ្លាំងស្តុក និងឡសម្ងួតស្រូវ ដែលមានទឹកប្រាក់សរុបប្រមាណ ១០ លានដុល្លារអាមេរិក សម្រាប់ទីតាំងខេត្តចំនួន ៣ គឺខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង។

សន្និសីទសារព័ត៌មានស្តីពី វិធានការរក្សាតម្លៃស្រូវបានសមរម្យក្នុងរដូវប្រមូលផលស្រូវ

ទីស្តីការគណៈរដ្ឋមន្ត្រី÷ ព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ **ឯកឧត្តម កៅ ថាច** អគ្គនាយក នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានអញ្ជើញ ចូលរួមជាវាគ្មិនក្នុងសន្និសីទសារព័ត៌មានស្តីពី វិធានការរក្សាតម្លៃបានសមរម្យក្នុងរដូវប្រមូលផលស្រូវ។

សន្និសីទនេះមានទិសដៅ និងគោលបំណង បង្ហាញពីការខិតខំប្រឹងប្រែងរបស់ **រាជរដ្ឋាភិបាល** ក្នុងកិច្ចចូលរួមសម្រួលស្ថិរភាពតម្លៃស្រូវ នារដូវប្រមូលផល។

ក្នុងឱកាសនេះផងដែរ **ឯកឧត្តម កៅ ថាច** បានលើកឡើងពីយន្តការឆ្លើយតបរបស់ **រាជរដ្ឋាភិបាល** ក្នុងការរក្សាស្ថេរភាពតម្លៃស្រូវក្រោយពីធ្លាក់ចុះតម្លៃ អំឡុងរដូវប្រមូលផល។ ក្នុងនោះ **រាជរដ្ឋាភិបាល** បានសម្រេចផ្តល់ថវិកាជាតិជាបន្តបន្ទាប់ ដើម្បីអន្តរាគមន៍ក្នុងការប្រមូលទិញស្រូវ និងសម្រាប់ធ្វើឃ្លាំងស្តុក និងឡសម្ងួតស្រូវ។ ការអន្តរាគមន៍នេះ បានធ្វើឱ្យតម្លៃស្រូវឡើងរហូតដល់ជាង ១ ០០០ រៀល ហើយតម្លៃមុនពេលធ្វើអន្តរាគមន៍ តម្លៃទីផ្សារគឺទាបជាង ៩០០រៀល។

កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០

ខេត្តមណ្ឌលគិរី÷ នៅព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០ ដែលប្រព្រឹត្តទៅនៅភូមិដំណាក់នាគ ខេត្តមណ្ឌលគិរី។

បន្ទាប់ពីការធ្វើបទបង្ហាញរាយការណ៍លទ្ធផលរបស់លោកអគ្គនាយករង និងប្រធាននាយកដ្ឋាន អំពីការអនុវត្តការងារសម្រេចបានក្នុងឆ្នាំ២០១៩ និងលើកទិដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០ **ឯកឧត្តម កៅ ថាច** បានអបអរសាទរនិងវាយតម្លៃខ្ពស់ ចំពោះសមិទ្ធផលដែលសម្រេចបានដ៏ល្អប្រសើររបស់នាយកដ្ឋាននិងអង្គភាពគ្រប់ផ្នែកទាំងអស់ ដែលបានខិតខំបំពេញការងារបានល្អប្រសើរ ហើយសមិទ្ធផលសម្រេចបានទាំងអស់នេះគឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីការរីកចម្រើនរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំរបស់ធនាគារអភិវឌ្ឍជនបទ និងកសិកម្ម។

ពិធីចុះកិច្ចព្រមព្រៀងផលិតកម្មដំណាំស្រូវតាមកិច្ចសន្យារវាងសហគមន៍កសិកម្មចំនួន១៦ ជាមួយ រោងម៉ាស៊ីនកិនស្រូវ ឈុន ធំ លើផលិតកម្មគ្រាប់ពូជស្រូវចំណី ពូជស្រូវសែនក្រអូប និងផ្ការំដួល

ខេត្តព្រៃវែង÷ រសៀល ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ **ឯកឧត្តម កៅ ថាច** អគ្គនាយក នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងសហការី បានអញ្ជើញចូលរួមជាសធ្វីភាពក្នុងពិធីចុះកិច្ចព្រមព្រៀងផលិតកម្មដំណាំស្រូវតាមកិច្ចសន្យារវាងសហគមន៍កសិកម្មចំនួន១៦ ជាមួយរោងម៉ាស៊ីនកិនស្រូវ ឈុន ធំ លើ ផលិតកម្មគ្រាប់ពូជស្រូវចំណី ពូជស្រូវសែនក្រអូប និងផ្កាំរំដួល លើផ្ទៃដី៧១៨ ហិកតា ដោយមានការជួយជ្រោមជ្រែងពីកម្មវិធីជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ (Rice SDP) និងគាំទ្រគម្រោងដោយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម លើការផ្តល់ទុនកម្ចីដល់រោងម៉ាស៊ីនសម្រាប់ទិញពូជស្រូវពីសហគមន៍កសិកម្ម។ ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តម កៅ ថាច** ក៏បានសំណូមពរ ដល់បងប្អូន សហគមន៍ផលិតពូជស្រូវ សូមធ្វើការផលិតប្រកបដោយគុណភាពខ្ពស់ និងមានបទដ្ឋានច្បាស់លាស់ ដោយក្នុងនោះ **ឯកឧត្តម កៅ ថាច** ស្នើសុំឱ្យមាន ជំនួយបច្ចេកទេសពីមន្ទីរកសិកម្មខេត្ត ដើម្បីត្រួតពិនិត្យមើលគុណភាពពូជស្រូវមុនធ្វើការផ្គត់ផ្គង់ចូលទីផ្សារ និងបន្តស្នើសុំការគាំទ្រគម្រោងនេះ ពីសំណាក់អាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក និងថ្នាក់ខេត្តផងដែរ។ ឯកឧត្តមមានជំនឿជាក់ថា តាមរយៈកិច្ចព្រមព្រៀងនេះនឹងនាំឱ្យមានការផ្លាស់ប្តូរវិជ្ជា លើការដាំដុះស្រូវ កាត់បន្ថយបានថ្លៃដើមផលិត និងបង្កើនទិន្នផលខ្ពស់ក្នុងដំណើរការខ្សែច្រវាក់ផលិតកម្មរបស់កសិករផងដែរ។

ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាល

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាព ដូចតទៅ÷

១. ឯកឧត្តម រស់ សីលវ៉ា (ប្រធាន)
២. ឯកឧត្តម សាន វិសាល (សមាជិក)
៣. ឯកឧត្តម កៅ ថាច (សមាជិក និងជាអគ្គនាយក)
៤. លោក សរ ចិត្រា (សមាជិក)
៥. លោក ទាន សុសេរី (សមាជិក)
៦. លោក អោម សេងបូរ៉ា (សមាជិក)
៧. លោក ចាន់ សីហា (សមាជិកតំណាងបុគ្គលិក)

គណៈកម្មការគ្រប់គ្រងហានិភ័យ

គណៈកម្មការគ្រប់គ្រងហានិភ័យគឺជាគណៈកម្មការក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។ គណៈកម្មការនេះមានតួនាទីទទួលខុសត្រូវចំពោះក្រុមប្រឹក្សាភិបាលលើការគ្រប់គ្រងហានិភ័យដូចខាងក្រោម÷

- ពិនិត្យ និងសម្រេចលើយុទ្ធសាស្ត្រគោលនយោបាយ គោលការណ៍ នីតិវិធី និងប៉ារ៉ាម៉ែត្រសមស្រប សម្រាប់គ្រប់គ្រងរាល់ហានិភ័យដែលអាចកើតឡើងចំពោះធនាគារ ហើយធ្វើការកែសម្រួលក្នុង ករណីចាំបាច់។
- ពិនិត្យទិន្នន័យហានិភ័យដែលរាយការណ៍ដោយថ្នាក់ដឹកនាំប្រតិបត្តិហើយ ប្រៀបធៀបជាមួយយុទ្ធសាស្ត្រគោលនយោបាយ គោលការណ៍ នីតិវិធី និងប៉ារ៉ាម៉ែត្រដែលបានកំណត់ដោយធនាគារ។
- ផ្តល់អនុសាសន៍ជូនថ្នាក់ដឹកនាំប្រតិបត្តិនិង ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងបញ្ហាគ្រប់គ្រងហានិភ័យ ក្នុងករណីចាំបាច់។
- ធានាភាពសមស្របនៃរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានផ្សេងៗទៀតដែលគាំទ្រការងារគ្រប់គ្រងហានិភ័យ។

គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្មគឺជាគណៈកម្មការឯករាជ្យ ដែលស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។គណៈកម្មការសវនកម្មមានតួនាទីពង្រឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងហានិភ័យ ដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃនីតិវិធីធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងនីតិវិធីសវនកម្ម។
- ធានាប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងហានិភ័យ។
- អនុម័តផែនការការងារសវនកម្មផ្ទៃក្នុង និងលទ្ធផលនៃការធ្វើសវនកម្មផ្ទៃក្នុងដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច។
- ការធានាភាពត្រឹមត្រូវនៃរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ។

ក្រុមប្រឹក្សាវិន័យ

ក្រុមប្រឹក្សាវិន័យគឺជាគណៈកម្មការពិសេសមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំប្រតិបត្តិ។ គណៈកម្មការនេះមានតួនាទីដូចខាងក្រោម÷

- ពិនិត្យនិងវាយតម្លៃលើសំណើសុំតែងតាំង និងដំឡើងឋានៈ ដោយផ្អែកលើគុណសម្បត្តិ។
- ពិនិត្យអំពីភាពសមស្របនៃកម្រិតប្រាក់បៀវត្ស និងលាភការផ្សេងៗរបស់បុគ្គលិក។
- ពិនិត្យនិងវាយតម្លៃលើការលើកទឹកចិត្ត និង ផ្តល់រង្វាន់ជូនបុគ្គលិក ដោយផ្អែកលើលទ្ធផលការងារ វិសេសវិសាល។
- ពិនិត្យនិងវាយតម្លៃលើការដាក់ទណ្ឌកម្មចំពោះបុគ្គលិកដែលមិនគោរពវិន័យ ដូចបានចែងក្នុងលក្ខន្តិកៈបុគ្គលិក។
- ពិនិត្យ និងស៊ើបអង្កេតអំពីករណីខុសឆ្គងរបស់បុគ្គលិកគ្រប់ថ្នាក់ ហើយចាត់វិធានការបើចាំបាច់។

រចនាសម្ព័ន្ធធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម



ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល

ឯកឧត្តម រស់ សីលវ៉ា

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ប្រធានក្រុមប្រឹក្សាភិបាល

បច្ចុប្បន្នឯកឧត្តម រស់ សីលវ៉ា ជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

ឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៧ ឯកឧត្តមបានបំពេញការងារជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍នៃ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ នៅឆ្នាំ១៩៩៣ ឯកឧត្តមបានបំពេញការងារ ជាសាស្ត្រាចារ្យនៅវិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញ នៃក្រសួងអប់រំ យុវជន និងកីឡា។

ចាប់តាំងពីឆ្នាំ១៩៩៤ ឯកឧត្តមបំពេញការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។

ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ឯកឧត្តម ជានាយករងផែនការគោលនយោបាយសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុ និងត្រួតពិនិត្យ។

ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៦ ឯកឧត្តមជានាយកនៃនាយកដ្ឋានសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។

ឯកឧត្តម ត្រូវបានតែងតាំងជាអគ្គលេខាធិការរងនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីឯកឧត្តមវិលត្រឡប់មកពីបំពេញការងារជាទីប្រឹក្សានាយកប្រតិបត្តិធនាគារពិភពលោក អំឡុងឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ហើយឯកឧត្តមត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ២០១៣។

ឯកឧត្តមក៏ជាអ្នករួមចំណែកក្នុងការតាក់តែងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងទាក់ទងការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ។

ឯកឧត្តម ទទួលបានបរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រសង្គម ពីវិទ្យាស្ថានគរុកោសល្យប៉េនហ្សា (BA in Social Science from Penzas Institute of Pedagogy) អតីតសហភាពសូវៀត នៅឆ្នាំ១៩៩២។ នៅឆ្នាំ២០០២ ឯកឧត្តមទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកកិច្ចការអន្តរជាតិគ្រប់គ្រងនយោបាយសេដ្ឋកិច្ចពី សាកលវិទ្យាល័យកូឡុមប៊ី ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។

ឯកឧត្តម សាន វិសាល

រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ឯកឧត្តម សាន វិសាល ជារដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

ពីឆ្នាំ១៩៩០ ដល់ ឆ្នាំ២០០៥ ឯកឧត្តមបានបំពេញការងារ ជាមន្ត្រីបច្ចេកទេសនៅ នាយកដ្ឋានគ្រឿងយន្តកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងការិយាល័យបមាណីយសំភារៈកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ពី ឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ឯកឧត្តមជាប្រធានមន្ទីរសាលាខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ។

ក្រៅពីបំពេញការងាររដ្ឋ ឯកឧត្តមមានបទពិសោធន៍ការងារក្នុងវិស័យឯកជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ចាប់ពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន ឯកឧត្តមជាអគ្គលេខាធិការ នៃសហព័ន្ធនិស្សិតបញ្ញវ័ន្តប្រជាធិបតេយ្យកម្ពុជា (ក្រុម២២)។

ឯកឧត្តមទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា នៅឆ្នាំ២០០៥ ហើយឯកឧត្តមបានបំពេញវគ្គបណ្តុះបណ្តាលសំខាន់ៗផងដែរ៕

ឯកឧត្តម កៅ ថាច

អគ្គនាយក ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តមបណ្ឌិតត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.) នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធ.អ.ជ.ក.។ ឯកឧត្តមក៏ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ និងធ្លាប់ជាមជ្ឈត្តករនៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចាប់តាំងពីឆ្នាំ២០០៣។

មុនទទួលតំណែងជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ឯកឧត្តមធ្លាប់បំពេញការងារជាអគ្គ-នាយករងនៃគណៈកម្មការមូលបត្រកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ និងជាប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការងារក្នុងផ្នែកច្បាប់ ឯកឧត្តមធ្លាប់ជាមន្ត្រីច្បាប់នៅក្រសួងយុត្តិធម៌ និងនៅតុលាការផងដែរ។

ឯកឧត្តមគឺជាសមាជិកក្រុមការងារក្នុងការរៀបចំបង្កើតគណៈកម្មការមូលបត្រកម្ពុជា និងទីផ្សារមូលបត្រនៅកម្ពុជា។ ជាមួយគ្នានេះដែរ ឯកឧត្តមបានបំពេញការងារជាច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលរួមមាន ការចូលរួមរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីមូលបត្ររដ្ឋ និងសេចក្ដីព្រាងច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងជាសមាជិកក្រុមការងារដែលទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងឆ្នាំ២០១១-២០២០។

ក្នុងនាមជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមគឺជាសមាជិកក្រុមការងារក្របខ័ណ្ឌអាស៊ានពាក់ព័ន្ធនឹងការអភិវឌ្ឍទីផ្សារទុនដូចជា ACMF, ABMI, CMI, WG-FSL, WG-CAL ជាដើម។

ពាក់ព័ន្ធនឹងការសិក្សា ឯកឧត្តមទទួលបានបរិញ្ញាបត្រនីតិសាស្ត្រពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ១៩៩៨ និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រពី សាកលវិទ្យាល័យ Bond នៃប្រទេសអូស្ត្រាលី នៅឆ្នាំ២០០២ ដែលការសិក្សាក្នុងបរិញ្ញាបត្រជាន់ខ្ពស់នេះផ្ដោតលើប្រព័ន្ធច្បាប់ពាណិជ្ជកម្មអន្តរជាតិ ក្របខ័ណ្ឌគតិយុត្តនៃអង្គការពាណិជ្ជកម្មពិភពលោក និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងឆ្នាំ២០១៩ ឯកឧត្តម ទទួលបានសញ្ញាបត្របណ្ឌិតផ្នែកពាណិជ្ជសាស្ត្រ (Doctor of Business Administration) ពី EU Business School។ និក្ខេបបទថ្នាក់បណ្ឌិតរបស់ឯកឧត្តមគឺ *"ប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ: ករណីសិក្សានៅប្រទេសកម្ពុជា"*។

លោក សរ ចិត្រា

អគ្គលេខាធិការរង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន លោក សរ ចិត្រា ជាអគ្គលេខាធិការរង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយជាសមាជិកក្រុមប្រឹក្សាភិបាលធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

លោក សរ ចិត្រា បានបម្រើការងារ និងមានបទពិសោធន៍ជាច្រើន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាំងពីឆ្នាំ២០០៥ មកម្ល៉េះ ក្នុងនោះគឺ÷

- ខែមិថុនា ឆ្នាំ១៩៩៥ ដល់ខែមេសា ឆ្នាំ១៩៩៩: ជាមន្ត្រីការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- ខែតុលា ឆ្នាំ២០០៥ ដល់ខែធ្នូ ឆ្នាំ២០០៧: ជាអនុប្រធានការិយាល័យផលិតកម្ម នៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
- ខែធ្នូ ឆ្នាំ២០០៧ ដល់ ខែមិថុនា ឆ្នាំ២០១១: ជាប្រធានការិយាល័យផលិតកម្ម នៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
- ខែមិថុនា ឆ្នាំ២០១១ ដល់ខែមីនា ឆ្នាំ២០១៤: ជាអនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- មីនា ឆ្នាំ២០១៤ ដល់ខែធ្នូ ឆ្នាំ២០១៦: ជាអគ្គលេខាធិការរង ទទួលបន្ទុកនាយកដ្ឋានផែនការ និងស្ថិតិ និងនាយកដ្ឋានកិច្ចការរដ្ឋបាល។

លោក សរ ចិត្រា បានបញ្ចប់ការសិក្សាបណ្ឌិតផ្នែកវិទ្យាសាស្ត្រសត្វ ពីសាកលវិទ្យាល័យអ៊ីវ៉ាតេ ប្រទេសជប៉ុនក្នុងឆ្នាំ២០០៥ និង បានទទួលសញ្ញាបត្រ អនុបណ្ឌិតវិទ្យាសាស្ត្រសត្វ ពី សាកលវិទ្យាល័យ Iwate ប្រទេសជប៉ុនក្នុងឆ្នាំ ២០០២៕

ឯកឧត្តមលោក ទាន សុសេរី

អគ្គនាយករង នៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង
ទីស្តីការគណៈរដ្ឋមន្ត្រី
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ននេះ ឯកឧត្តម គឺជាជំនួយការឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

ឯកឧត្តមធ្លាប់បំពេញការងារជា ប្រធានផ្នែករដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ និងជាប្រធានផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងអប់រំ នៃនាយកដ្ឋានការពារនិងអប់រំ ក្នុងឆ្នាំ ២០០៩ នៅអាជ្ញាធរដែនដីជាតិ “គណៈរដ្ឋមន្ត្រី” ផងដែរ។

ឯកឧត្តម ទាន សុសេរី កំពុងសិក្សាបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ នៅរាជបណ្ឌិតសភាកម្ពុជា។

លោក អោម សេងបូរ៉ា

តំណាងអភិបាលឯករាជ្យ
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន លោក អោម សេងបូរ៉ា ជាតំណាងអភិបាលឯករាជ្យ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ហើយលោកក៏ជាអភិបាលឯករាជ្យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងជាសមាជិកនៃសភាពាណិជ្ជកម្មកម្ពុជាផងដែរ។

ក្រៅពីការបំពេញការងាររដ្ឋ លោកមានមុខតំណែង និងបទពិសោធន៍ទាំងផ្នែកឯកជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ លោកជាអគ្គនាយកប្រតិបត្តិនៃអង្គការ Vision Fund កម្ពុជា។ ពីឆ្នាំ២០១០ មកដល់បច្ចុប្បន្ន លោកគឺជាប្រធានក្រុមហ៊ុន Aplus Counsulting and Aplus School for Professionals និងជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា។ ឆ្នាំ២០១៣ ដល់បច្ចុប្បន្ន លោកជាសមាជិកស្ថាបនិក និងក្រុមប្រឹក្សាភិបាលនៃ ក្លឹបវិនិយោគិនកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃបណ្តាញចាប់ផ្តើមអាជីវកម្ម។ ឆ្នាំ២០១៤ ដល់បច្ចុប្បន្ន លោកជាអភិបាលឯករាជ្យនៃអង្គការ Teuk Saat 1001 និងជាស្ថាបនិកនិងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Cambodia Empire Group។

លោកបានបញ្ចប់ការសិក្សាសញ្ញាប័ត្រជាន់ខ្ពស់គ្រប់គ្រងអាជីវកម្ម នៅសាកលវិទ្យាល័យ Preston ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៨ និង បរិញ្ញាប័ត្រគ្រប់គ្រង ជំនាញគណនីពីសាកលវិទ្យាល័យ Maharishi Vedic កម្ពុជា ក្នុងឆ្នាំ១៩៩៨៕

លោក ចាន់ សីហា

តំណាងបុគ្គលិក
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន លោក ចាន់ សីហា គឺជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានឥណទាន និងនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម និងយុទ្ធសាស្រ្ត និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម តំណាងបុគ្គលិក។

លោកបានបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទចាប់ពីខែមករា ឆ្នាំ១៩៩៩ ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវបានតែងតាំងជាអគ្គនាយករងទទួលបន្ទុកនៅខែកក្កដា ឆ្នាំ២០១២។

ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៩ លោកបានបម្រើការងារជាអនុប្រធានការិយាល័យគ្រប់គ្រងគណនី និងជាប្រធានផ្នែក នៃការិយាល័យសភាផាត់ទាត់ នាយកដ្ឋានប្រតិបត្តិការនិងជាបុគ្គលិកគណនេយ្យនៃនាយកដ្ឋានគណនេយ្យ នៃធនាគារជាតិនៃកម្ពុជា។

លោកបានទទួលបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាប័ត្រផ្នែកធនាគារ ពីសាកលវិទ្យាល័យធនាគារ ប្រទេសវៀតណាម ក្នុងឆ្នាំ១៩៩១។

ប្រវត្តិរូបសង្ខេបរបស់គណៈគ្រប់គ្រង

ឯកឧត្តមបណ្ឌិត កៅ ថាច
អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ឯកឧត្តមបណ្ឌិតត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ័.ជ.ក.) នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធ.អ.ជ.ក.។ ឯកឧត្តមក៏ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ និងធ្លាប់ជាមជ្ឈត្តករនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ចាប់តាំងពីឆ្នាំ២០០៣។

មុនទទួលតំណែងជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ឯកឧត្តមធ្លាប់បំពេញការងារជាអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ និងជាប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការងារក្នុងផ្នែកច្បាប់ ឯកឧត្តមធ្លាប់ជាមន្ត្រីច្បាប់នៅក្រសួងយុត្តិធម៌ និងនៅតុលាការផងដែរ។

ឯកឧត្តមគឺជាសមាជិកក្រុមការងារក្នុងការរៀបចំបង្កើតគណៈកម្មការមូលបត្រកម្ពុជា និងទីផ្សារមូលបត្រនៅកម្ពុជា។ ជាមួយគ្នានេះដែរ ឯកឧត្តមបានបំពេញការងារជាច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលរួមមាន ការចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងជាសមាជិកក្រុមការងារដែលទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងឆ្នាំ២០១១-២០២០។

ក្នុងនាមជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមគឺជាសមាជិកក្រុមការងារក្របខ័ណ្ឌអាស៊ានពាក់ព័ន្ធនឹងការអភិវឌ្ឍទីផ្សារទុនដូចជា ACMF, ABMI, CMI, WG-FSL, WG-CAL ជាដើម។

ពាក់ព័ន្ធនឹងការសិក្សា ឯកឧត្តមទទួលបានបរិញ្ញាបត្រនីតិសាស្ត្រពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ១៩៩៨ និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រពី សាកលវិទ្យាល័យ Bond នៃប្រទេសអូស្ត្រាលី នៅឆ្នាំ២០០២ ដែលការសិក្សាក្នុងបរិញ្ញាបត្រជាន់ខ្ពស់នេះផ្តោតលើប្រព័ន្ធច្បាប់ពាណិជ្ជកម្មអន្តរជាតិ ក្របខ័ណ្ឌគតិយុត្តនៃអង្គការពាណិជ្ជកម្មពិភពលោក និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងឆ្នាំ២០១៩ ឯកឧត្តម ទទួលបានសញ្ញាបត្របណ្ឌិតផ្នែកពាណិជ្ជសាស្ត្រ (Doctor of Business Administration) ពី EU Business School។ និក្ខេបបទថ្នាក់បណ្ឌិតរបស់ឯកឧត្តមគឺ “ប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ: ករណីសិក្សានៅប្រទេសកម្ពុជា”។

ឯកឧត្តមបណ្ឌិត សឹង រេត

អគ្គនាយករងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

បច្ចុប្បន្ន ឯកឧត្តមបណ្ឌិត សឹង រេត ជាអគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ទទួលបន្ទុកនាយកដ្ឋានប្រតិបត្តិការ និងហិរញ្ញប្បទានពាណិជ្ជកម្ម នាយកដ្ឋានកិច្ចការរតនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ និងនាយកដ្ឋានព័ត៌មានវិទ្យា និងយុទ្ធសាស្ត្រប្រតិបត្តិការធនាគារបែបឌីជីថល។ ឯកឧត្តមត្រូវបានតែងតាំងជាអគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ចាប់ពីខែកក្កដា ឆ្នាំ២០១៩។

ឯកឧត្តមជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើរដ្ឋលេខាធិការផងដែរ។ ជាមួយគ្នានេះដែរ ឯកឧត្តមបណ្ឌិត គឺជាសមាជិកនៃមហាវិទ្យាល័យធុរៈកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃសាកលវិទ្យាល័យ Antwerp នៃប្រទេសប៊ែលហ្ស៊ិក និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច (Research Follow) នៅមជ្ឈមណ្ឌលសម្រាប់ការសិក្សា ASEAN (Centre for ASEAN Studies)។ ឯកឧត្តមធ្លាប់ជាសាស្ត្រាចារ្យបង្រៀនសេដ្ឋកិច្ច នៅរដ្ឋ Massachusetts សហរដ្ឋអាមេរិក ក្រោមកម្មវិធី Fulbright Lecturing Program នៃ U.S Department of department។ អំឡុងកម្មវិធី Fullbright នៅសហរដ្ឋអាមេរិក ឯកឧត្តម ត្រូវបានអញ្ជើញជាញឹកញាប់មកបង្រៀន នៅ D"Amore-McKim School of Business នៃសាកលវិទ្យាល័យ Northeastern ក្រុង Boston រដ្ឋ Massachusetts សហរដ្ឋអាមេរិក។ ឯកឧត្តមក៏ជាសាស្ត្រាចារ្យផ្នែកសេដ្ឋកិច្ចនៃសាលាភូមិន្ទរដ្ឋបាល និងជាសាស្ត្រាចារ្យជាន់ខ្ពស់ ក្នុងដេប៉ាតេម៉ង់សិក្សាអន្តរជាតិ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ជាមួយគ្នានេះដែរ ឯកឧត្តមធ្លាប់ជាសមាជិកគណៈវិនិច្ឆ័យសម្រាប់ការការពារនិក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់ នៅសកលវិទ្យាល័យ Antwerp និងជាសមាជិកពិនិត្យការការពារនិក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសកម្ពុជា។

ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៩ ដល់ខែមករា ឆ្នាំ២០១១ ឯកឧត្តម បានបញ្ចប់កិច្ចការស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតនៅ Flemish Center for International Policy សាកលវិទ្យាល័យ Antwerp ដែលជាកន្លែងដែលឯកឧត្តមបានធ្វើការលើគម្រោងស្រាវជ្រាវរួមគ្នាជាមួយធនាគារជាតិនៃប្រទេសប៊ែលហ្ស៊ិក ក្រោមប្រធានបទ ឥទ្ធិពលនៃសកលភាវូបនីយកម្មលើទីផ្សារការងារក្នុងប្រទេសប៊ែលហ្ស៊ិក។ ឯកឧត្តមធ្លាប់ជាអ្នកត្រួតពិនិត្យលើឯកសារសម្រាប់ទិន្នានុប្បវត្តិជាច្រើន ដូចជា Journal of Asian Economics, International Trade Journal, Economics Bulletin, International Journal of Commerce and ManagementJournal of International Trade and Economic Development, Journal of Asian Economics, International Journal of Manpower, Journal of International Trade Law and Policy។ ការងារស្រាវជ្រាវរបស់ឯកឧត្តម ក៏ត្រូវបានទទួលឱ្យធ្វើបទបង្ហាញនៅសហរដ្ឋអាមេរិក ប្រទេសចិន ប្រទេសហ្វីលីពីន ប្រទេសប៊ែលហ្ស៊ិក ប្រទេសកូរ៉េ ប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរី និងប្រទេសថៃផងដែរ។ បច្ចុប្បន្ន ឯកឧត្តមក៏ជាសមាជិកនៃក្រុមប្រឹក្សាត្រួតពិនិត្យនៃ Journal of Business and Management ហើយក៏ជាសមាជិក (Council of Fellows) នៃ East Asian and Economic Association (EAEA)។

សម្រាប់ការសិក្សា ឯកឧត្តមទទួលបានសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រគណិតវិទ្យា បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងបណ្ឌិតសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Antwerp ប្រទេសប៊ែលហ្ស៊ិក ក្រោម កម្មវិធីអាហារូបករណ៍របស់រាជរដ្ឋាភិបាលប៊ែលហ្ស៊ិក។ និក្ខេបបទថ្នាក់បណ្ឌិតរបស់ឯកឧត្តម គឺ "Foreign Direct Investment in Cambodia: Determinants and Impacts on Domestic Labor Productivity and International Trade"។

លោក ចាន់ សីហា

អគ្គនាយករងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

លោក ចាន់ សីហា គឺជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានឥណទាន នាយកដ្ឋានគ្រប់គ្រងសាខា និងប្រតិបត្តិការចល័ត និងនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម និងយុទ្ធសាស្រ្ត និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម តំណាងបុគ្គលិក។
លោកបានបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទចាប់ពីខែមករា ឆ្នាំ១៩៩៩ ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវបានតែងតាំងជាអគ្គនាយករងទទួល   បន្ទុកនៅខែកក្កដា ឆ្នាំ២០១២។

ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៩ លោកបានបម្រើការងារជាអនុប្រធានការិយាល័យគ្រប់គ្រងគណនី និងជាប្រធានផ្នែក នៃការិយាល័យសភាផាត់ទាត់ នាយកដ្ឋានប្រតិបត្តិការនិងជាបុគ្គលិកគណនេយ្យនៃនាយកដ្ឋានគណនេយ្យ នៃធនាគារជាតិនៃកម្ពុជា។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាប័ត្រផ្នែកធនាគារ ពីសាកលវិទ្យាល័យធនាគារ ប្រទេសវៀតណាម ក្នុងឆ្នាំ១៩៩១។

លោក ម៉ក់ សុផល

អគ្គនាយករងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

គឺជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងហានិភ័យ នាយកដ្ឋានកិច្ចការគតិយុត្ត និងប្រតិបត្តិតាម និងនាយកដ្ឋានតាមដានការប្រមូល និងប្រើប្រាស់បំណុល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។
លោកបានចូលបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក្នុងខែមករា ឆ្នាំ ១៩៩៩ ជាប្រធាននាយកដ្ឋានឥណទាន និងត្រូវបានតែងតាំងជាអគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទ នៅខែមេសា ឆ្នាំ២០១៨។
ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨ លោកបានបម្រើការងារជាមន្ត្រីនៃនាយកដ្ឋានត្រួតពិនិត្យនៅធនាគារជាតិនៃកម្ពុជា និងបម្រើការងារក្រៅម៉ោងនៅធនាគារសន្តិភាពពាណិជ្ជចំកាត់។

លោកបានទទួលបរិញ្ញាបត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារនៅទីក្រុងហូជីមិញ ប្រទេសវៀតណាមនៅឆ្នាំ១៩៩៣។

លោក ប៊ិច សានី

អគ្គនាយករងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

លោក ប៊ិច សានី គឺជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានធនធានមនុស្ស និងបណ្តុះបណ្តាល និងនាយកដ្ឋានរដ្ឋបាលទូទៅ និងទំនាក់ទំនងសាធារណៈនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

លោក ប៊ិច សានី មានបទពិសោធន៍ការងារក្នុងវិស័យធនាគារជាង២០ឆ្នាំមកហើយ។ មុននឹងចូលបម្រើការងារនៅធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ក្នុងឆ្នាំ២០០១ លោកបានបម្រើការងារក្នុងបទពិសោធន៍និងមុខនាទីការងារជាច្រើននៅធនាគារជាតិ នៃកម្ពុជា និងនៅធនាគារពាណិជ្ជ។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៤ និងបរិញ្ញាបត្រផ្នែកធនាគារ ពីសាកលវិទ្យាល័យធនាគារ ប្រទេសវៀតណាម ក្នុងឆ្នាំ១៩៩១។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ
និងកសិកម្ម)

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019
និង
របាយការណ៍របស់សវនករឯករាជ្យ

ព័ត៌មានអំពីធនាគារ

ធនាគារ	**ធនាគារ អភិវឌ្ឍន៍ជនបទ** (បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)	
ចុះបញ្ជីពាណិជ្ជកម្មលេខ	Co.3942 et/1998	
ទីស្នាក់ការចុះបញ្ជី	អគារលេខ 9-13 ផ្លូវ លេខ 7 សង្កាត់ ចតុមុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា	
ម្ចាស់ភាគហ៊ុន	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	
ក្រុមប្រឹក្សាភិបាល	ឯកឧត្តម សេ សីលវ៉ា	ប្រធានក្រុមប្រឹក្សាភិបាល
	ឯកឧត្តម សាន វិសាល	សមាជិក
	ឯកឧត្តម កៅ ថាច	សមាជិក
	លោក សរ ចិត្រា	សមាជិក
	លោក ទាន សុសេរី	សមាជិក
	លោក អោម សេងបូរ៉ា	សមាជិក
	លោក ដេត វាសនា	សមាជិក
	លោក ចាន់ សីហា	សមាជិក
អ្នកគ្រប់គ្រង	ឯកឧត្តម កៅ ថាច	អគ្គនាយក
	ឯកឧត្តម សឹង វេត	អគ្គនាយករង
	លោក ចាន់ សីហា	អគ្គនាយករង
	លោក អ៊ុច ចន្ថា	ប្រធានគណៈកម្មការគាំទ្រគោលនយោបាយរបស់រដ្ឋាភិបាល
	លោក ប៉ិច សានី	អគ្គនាយករង
	លោក ម៉ក់ សុផល	អគ្គនាយករង
	លោក នង ធារិទ្ធ	ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
	លោក នេត បញ្ញា	ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងប្រតិបត្តិការ និងជាប្រធានលេខា
	លោក ខែក ពិសិដ្ឋ	ប្រធាននាយកដ្ឋានប្រតិបត្តិការ និងកិច្ចការរតនាគារ
	លោកស្រី អ៊ឹង ពិសិដ្ឋណាលីន	ប្រធាននាយកដ្ឋានធនធានមនុស្ស និងបណ្តុះបណ្តាល
	លោក មិត្ត ប៊ុន	ប្រធាននាយកដ្ឋានឥណទាន

ព័ត៌មានអំពីធនាគារ (ត)

អ្នកគ្រប់គ្រង (ត)	លោក អ៊ឹង សុង	ប្រធាននាយកដ្ឋាន តាមដានការប្រើប្រាស់ ឥណទាន និងប្រមូលបំណុល
	លោកស្រី សាន គឹមមួយ	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្មយុទ្ធសាស្ត្រ
	លោក ថាត ចាន់ថាគៀ	ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ
	លោក ញ៉ឹប រ៉ាទី	ប្រធាននាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម និង គ្រឹះស្ថានហិរញ្ញវត្ថុ
	លោក ជិន ជ័យាបុត្រ	ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ និងទំនាក់ទំនងសាធារណៈ និងជាអនុប្រធានលេខាធិការដ្ឋាន
	លោក ម៉ិច សំរិន	ប្រធានស្តីទីនាយកដ្ឋានព័ត៌មានវិទ្យា និង យុទ្ធសាស្ត្រឌីជីថល
	លោក សុខុមដារ៉ារដ្ឋ	ប្រធានស្តីទីនាយកដ្ឋានគ្រប់គ្រងសាខា និង ប្រតិបត្តិការចល័ត
	លោកស្រី ឈុន សុខា	ប្រធានស្តីទីនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
	លោកស្រី សួន ថារី	ប្រធានស្តីទីនាយកដ្ឋានសវនកម្មផ្ទៃក្នុង
សវនករ	ខេភីអឹមជី ខេមបូឌា ចំកាត់	

ធនាគារ អភិវឌ្ឍន៍ជនបទ
(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

មាតិកា

		ទំព័រ
1.	របាយការណ៍របស់ក្រុមប្រឹក្សាភិបាល	1 – 6
2.	របាយការណ៍របស់សវនករឯករាជ្យ	7 – 11
3.	របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	12 – 13
4.	របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ	14
5.	របាយការណ៍ស្តីពីបម្រែបម្រួលមូលធន	15 – 16
6.	របាយការណ៍លំហូរទឹកប្រាក់	17 – 19
7.	កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ	20 – 136

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

លេខ / N° : .... ធ.អ.ជ.ក. / ARDB

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្ដីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍន៍ជនបទ (បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម) ហៅកាត់ថា ("ធនាគារ") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ។

សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារ គឺការផ្ដល់នូវធនធានហិរញ្ញវត្ថុដល់ធនាគារពាណិជ្ជកម្ម និងធនាគារឯកទេស និងមីក្រូហិរញ្ញវត្ថុ ដែលចូលរួមក្នុងការផ្ដល់នូវសេវាកម្មឥណទាននិងប្រាក់សន្សំសម្រាប់ក្រុមគ្រួសារនៅតំបន់ជនបទ និងអាជីវកម្មខ្នាតតូច ។ ទន្ទឹមនឹងនេះ ក៏មានការរួមបញ្ចូលនូវការអនុវត្តគម្រោងអភិវឌ្ឍន៍តាមការស្នើសុំពីដៃគូអនុវត្ត ដែលគម្រោងអភិវឌ្ឍន៍ទាំងនោះ មិនអាចត្រូវបានអនុវត្តដោយប្រតិបត្តិករមីក្រូហិរញ្ញវត្ថុនោះទេ ហើយការផ្ដល់នូវថវិកាដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍ពិសេសរបស់រាជរដ្ឋាភិបាល ឬគម្រោងអភិវឌ្ឍន៍ពិសេសផ្សេងទៀតដោយមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការផ្លាស់ប្ដូរសកម្មភាពចម្បង ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 1 នៃរបាយការណ៍ហិរញ្ញវត្ថុ ។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 មានដូចខាងក្រោម៖

	2019 ដុល្លារអាមេរិក	2018 ដុល្លារអាមេរិក	2019 ពាន់រៀល (កំណត់សម្គាល់ 5)	2018 ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់ចំណេញមុនបង់ពន្ធ	8,412,681	2,380,415	34,088,183	9,628,780
ចំណាយពន្ធលើប្រាក់ចំណេញ	(1,739,777)	(276,136)	(7,049,576)	(1,116,970)
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	6,672,904	2,104,279	27,038,607	8,511,810

ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយក្រុមប្រឹក្សាភិបាល ក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានធ្វើសវនកម្មនេះទេ ។

អគារលេខ ៩-១៣ វិថីលេខ ៧ សង្កាត់ចតុមុខ ប្រអប់សំបុត្រលេខ ១៤១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
9-13, St. 7, Sangkat Chaktomuk, PO Box : 1410. Phnom Penh,,Cambodia.
E-mail : admin@ardb.com.kh
ទូរសព្ទ (៨៥៥)២៣ ២២០ ៨១០/ ២២០ ៨១១ Tel : (855)23 220 810/220 811
Web site : www.ardb.com.kh
Facebook : Agricultural and Rural Development Bank of Cambodia

ធនាគារ អភិវឌ្ឍន៍ជនបទ
(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

ដើមទុន

ការផ្លាស់ប្តូរភាគហ៊ុន និងវចនាសម្ព័ន្ធភាគហ៊ុនត្រូវបានបង្ហាញនៅកំណត់សម្គាល់ 19 នៃរបាយការណ៍ហិរញ្ញវត្ថុ។

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ឥណទាន និងបុរេប្រទាន

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយអ្នកគ្រប់គ្រងជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់លើការបាត់បង់ឥណទាន និងបុរេប្រទាន ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តលើកលែងបំណុល ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ហើយដែលសន្និដ្ឋានថា មានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថា នឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវនោះទេ ។

វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

ធនាគារ អភិវឌ្ឍន៍ជនបទ
(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលធនាគារត្រូវបំពេញឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ នឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ ។

ការប្រែប្រួលសភាពការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានពិនិត្យឃើញសភាពការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សាខាធនាគារ ដែលអាចនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ ។

ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

ព្រឹត្តិការណ៍ចាប់តាំងពីការិយបរច្ឆេទនៃរបាយការណ៍

ការរំពឹងលើការបាត់បង់ឥណទាននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ត្រូវបានគេប៉ាន់ស្មានដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ចដែលបានព្យាករណ៍នាកាលបរិច្ឆេទនោះ ។ នាកាលបរិច្ឆេទបន្ទាប់ មានការផ្ទុះឡើងនៃវីរុសកូរ៉ូណា បានរីករាលដាលពាសពេញប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសដ៏ទៃទៀត ដែលបង្កឱ្យមានការរំខានដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច ។ ផលប៉ះពាល់លើកំណើនផលិតផលក្នុងស្រុកដុល (GDP) និងសូចនាករសំខាន់ផ្សេងៗនឹងត្រូវបានពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភាពដែលអាចទៅរួចនៃការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ដែលនឹងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការរំពឹងទុកលើការខាតបង់ឥណទានក្រោម ស.រ.ទ.ហ.អ.ក 9 ក្នុងឆ្នាំ 2020 ។

ធនាគារ អភិវឌ្ឍន៍ជនបទ
(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះរួមមាន៖

ឯកឧត្តម រស់ សីលវ៉ា	ប្រធានក្រុមប្រឹក្សាអភិបាល (អភិបាលមិនប្រតិបត្តិ)
ឯកឧត្តម សាន វិសាល	សមាជិកអភិបាល (អភិបាលមិនប្រតិបត្តិ)
ឯកឧត្តម កៅ ថាច	សមាជិកអភិបាល និង នាយកប្រតិបត្តិ (អភិបាលប្រតិបត្តិ)
លោក សរ ចិត្រា	សមាជិកអភិបាល (អភិបាលមិនប្រតិបត្តិ)
លោក ទាន សុសេរី	សមាជិកអភិបាល (អភិបាលមិនប្រតិបត្តិ)
លោក អោម សេងបូរ៉ា	សមាជិកអភិបាល (អភិបាលមិនប្រតិបត្តិ)
លោក ដេត វាសនា	សមាជិកអភិបាល (អភិបាលមិនប្រតិបត្តិ)
លោក ចាន់ សីហា	សមាជិកអភិបាល (អភិបាលប្រតិបត្តិ)

ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានអ្នកគ្រប់គ្រងណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ធនាគារដោយផ្ទាល់ឬដោយប្រយោល នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់អ្នកគ្រប់គ្រងណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃ ។

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នេះ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ បានរៀបចំឡើងយ៉ាងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ខ) អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាង ព័ត៌មានប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការ ធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំធនាគារឲ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់សាខាធនាគារ ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយដែលក្នុងមតិរបស់យើងខ្ញុំថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល៖

ឯកឧត្តម រស់ សីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល

ឯកឧត្តម កៅ ថាច
នាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 4 AUG 2020

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់
ធនាគារអភិវឌ្ឍន៍ជនបទ
(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

មតិសវនកម្មមានបញ្ហា

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍន៍ជនបទ (បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម) ហៅកាត់ថា ("ធនាគារ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 12 ដល់ទី 136 (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ លើកលែងតែផលប៉ះពាល់នៃបញ្ហាដែលបានរៀបរាប់នៅក្នុង *មូលដ្ឋាននៃសវនកម្មមានបញ្ហា*នៃរបាយការណ៍របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ។

មូលដ្ឋាននៃមតិសវនកម្មមានបញ្ហា

	ប្រភេទនៃរូបិយប័ណ្ណសមមូលដុល្លារអាមេរិក		
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	រៀល	ដុល្លារអាមេរិក	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ			
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	897,443	37,611,314	38,508,757
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	3,332,444	169,829,983	173,162,427
ទ្រព្យសកម្មផ្សេងៗ	4,400	1,004,152	1,008,552
	4,234,287	208,445,449	212,679,736
បំណុលហិរញ្ញវត្ថុ			
ប្រាក់បញ្ញើរបស់អតិថិជន	61,548	2,567,325	2,628,873
ប្រាក់បញ្ញើរបស់ធនាគារនានា	-	2,871	2,871
ប្រាក់កម្ចី	72,823,716	38,884,182	111,707,898
អនុបំណុល	-	1,044,084	1,044,084
បំណុលផ្សេងៗ	7,148	992,974	1,000,122
	72,892,412	43,491,436	116,383,848
ស្ថានភាព(បំណុល)/ទ្រព្យសកម្មសុទ្ធ	(68,658,125)	164,954,013	96,295,888
(សមមូលពាន់រៀល - កំណត់សម្គាល់ 5)	(279,781,859)	672,187,603	392,405,743

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

១. ហានិភ័យរូបិយប័ណ្ណបរទេស (ត)

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ (ត)

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម (ត) ៖

	ប្រភេទនៃរូបិយប័ណ្ណសមមូលដុល្លារអាមេរិក		
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	ពាន់រៀល	ដុល្លារអាមេរិក	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ			
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	1,432,107	13,964,503	15,396,610
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	3,282,310	155,832,898	159,115,208
ទ្រព្យសកម្មផ្សេងៗ	1,771	375,766	377,537
	4,716,188	170,173,167	174,889,355
បំណុលហិរញ្ញវត្ថុ			
ប្រាក់បញ្ញើរបស់អតិថិជន	8,158	3,457,467	3,465,625
ប្រាក់បញ្ញើរបស់ធនាគារនានា	-	24,769	24,769
ប្រាក់កម្ចី	73,952,140	53,351,851	127,303,991
អនុបំណុល	-	1,044,084	1,044,084
បំណុលផ្សេងៗ	541	2,189,390	2,189,931
	73,960,839	60,067,561	134,028,400
ស្ថានភាព(បំណុល)/ទ្រព្យសកម្មសុទ្ធ	(69,244,651)	110,105,606	40,860,955
(សមមូលពាន់រៀល - កំណត់សម្គាល់ 5)	(278,225,008)	442,404,325	164,179,317

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(i). ហានិភ័យរូបិយប័ណ្ណបរទេស (ត)

ការវិភាគរំញោច

សន្មតថាហានិភ័យអថេរផ្សេងទៀតនៅតែថេរជានិច្ច ការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេសសម្រាប់ធនាគារនាកាលបរិច្ឆេទរាយការណ៍ត្រូវបានសង្ខេបដូចខាងក្រោម (ដោយបង្ហាញតែរូបិយប័ណ្ណដែលមានចំនួនច្រើនជាង 5% នៃស្ថានភាពដំបូងសុទ្ធ ត្រូវបានបង្ហាញជារូបិយប័ណ្ណជាក់លាក់របស់វានៅក្នុងតារាងខាងក្រោម ។ សម្រាប់រូបិយប័ណ្ណផ្សេងទៀត ការលាតត្រដាងទាំងនេះត្រូវបានដាក់ជាក្រុម 'ផ្សេងៗ')៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	- 1% រំលស់ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក	- 1% រំលស់ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក
រៀល	686,581	(686,581)	692,447	(692,447)
ពាន់រៀល – កំណត់សម្គាល់ 5	2,797,818	(2,797,818)	2,782,252	(2,782,252)

ឃ. ហានិភ័យសាច់ប្រាក់ងាយស្រួល

"ហានិភ័យសាច់ប្រាក់ងាយស្រួល" គឺជាហានិភ័យដែលធនាគារនឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ចពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួលកើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលា និងចំនួនលំហូរទឹកប្រាក់ដែលមាននៅក្នុងប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ ។

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ឃ. ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

ធនាគារគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ខ្លួនតាមរយៈគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម បំណុលដែលទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយសាច់ប្រាក់ងាយស្រួល និងត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលជាប្រចាំ។ តម្រូវការទ្រព្យសកម្មងាយស្រួលអប្បបរមា ត្រូវបានបង្កើតឡើងដើម្បីធានាថាអនុបាតនៃទ្រព្យសកម្មងាយស្រួល និងបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា ។

តារាងខាងក្រោមសង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារដោយផ្អែកលើកាលកំណត់កិច្ចសន្យាដែលនៅសល់។ លំហូរទឹកប្រាក់ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះអាចខុសជាសារវន្តពីអ្វីដែលបានបង្ហាញនៅក្នុងតារាង។ ឧទាហរណ៍ ប្រាក់បញ្ញើរបស់អតិថិជនមិនត្រូវបានរំពឹងថានឹងត្រូវដកបានភ្លាមៗនោះទេ ។

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ឃ. ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	រហូតដល់ 1 ខែ ដុល្លារអាមេរិក	> 1 - 3 ខែ ដុល្លារអាមេរិក	> 3 - 12 ខែ ដុល្លារអាមេរិក	> 1 - 5 ឆ្នាំ ដុល្លារអាមេរិក	លើសពី 5 ឆ្នាំ ដុល្លារអាមេរិក	ពុំមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើរបស់អតិថិជន	1,957,284	172,453	499,136	-	-	-	2,628,873
ប្រាក់បញ្ញើរបស់ធនាគារនានា	681	-	-	-	-	2,190	2,871
ប្រាក់កម្ចី	-	-	-	344,568	111,363,330	-	111,707,898
អនុបំណុល	-	-	-	-	-	1,044,084	1,044,084
បំណុលផ្សេងៗ	-	-	-	-	-	1,000,122	1,000,122
	1,957,965	172,453	499,136	344,568	111,363,330	2,046,396	116,383,848
(សមមូលពាន់រៀល - កំណត់សម្គាល់ 5)	7,978,707	702,746	2,033,979	1,404,115	453,805,570	8,339,064	474,264,181

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ឃ. ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	រហូតដល់ 1 ខែ ដុល្លារអាមេរិក	>1-3 ខែ ដុល្លារអាមេរិក	>3-12 ខែ ដុល្លារអាមេរិក	>1-5 ឆ្នាំ ដុល្លារអាមេរិក	លើសពី 5 ឆ្នាំ ដុល្លារអាមេរិក	ពុំមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើរបស់អតិថិជន	2,540,249	24,788	900,588	-	-	-	3,465,625
ប្រាក់បញ្ញើរបស់ធនាគារនានា	695	-	-	-	-	24,074	24,769
ប្រាក់កម្ចី	-	-	-	637,791	126,666,200	-	127,303,991
អនុបំណុល	-	-	-	-	-	1,044,084	1,044,084
បំណុលផ្សេងៗ	-	-	-	-	-	2,189,931	2,189,931
	2,540,944	24,788	900,588	637,791	126,666,200	3,258,089	134,028,400
(សមមូលពាន់រៀល - កំណត់សម្គាល់ 5)	10,209,513	99,598	3,618,563	2,562,644	508,944,792	13,091,002	538,526,112

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ង. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក ឬប្រព័ន្ធ ឬពីកត្តាខាងក្រៅ។ ហានិភ័យនេះត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឲ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម តាមរយៈអង្គភាពគ្រប់គ្រង និងគាំទ្រ ដែលឯករាជ្យពីអង្គភាពអាជីវកម្ម និងគណៈគ្រប់គ្រង ។ ទាំងនេះរួមមាន ហានិភ័យខាងផ្នែកច្បាប់ តាមច្បាប់នៃការអនុលោមតាមគណនេយ្យ និងការក្លែងបន្លំ ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារ តម្រូវឲ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឲ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើន ត្រូវបានអនុវត្ត ។ គោលការណ៍ទាំងនេះ រួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារសំអាងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការ ដែលអាចកើតមានឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ។

ច. ការគ្រប់គ្រងដើមទុន

(i). បទប្បញ្ញត្តិដើមទុន

គោលដៅរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិ
- ការពារលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះ ធនាគារអាចបន្ត ផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម ។

គោលនយោបាយរបស់ធនាគារ គឺធានាឲ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍឍអង្វែងរបស់អាជីវកម្ម ។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ធនាគារ ក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការ ដើម្បីធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ ដែលអាចនឹងកើតមានឡើងជាមួយនឹងប្រាក់បម្រុងកម្រិតខ្ពស់អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ ។

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ច. ការគ្រប់គ្រងដើមទុន (ត)

(i). បទប្បញ្ញត្តិដើមទុន (ត)

ដើមទុនបង្ហាញខាងលើនេះ ត្រូវបានគណនាឡើងដោយផ្អែកតាមសេចក្តីណែនាំដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ដែលអាចមានភាពខុសគ្នាទៅលើគោលការណ៍សំខាន់ខ្លះៗ បើប្រៀបធៀបទៅនឹងគោលការណ៍ដែលបានទទួលស្គាល់ជាទូទៅ ដែលស្ថាប័នហិរញ្ញវត្ថុនៅប្រទេសដទៃបានអនុវត្ត។ ដូច្នេះ ព័ត៌មានអំពីដើមទុនខាងលើ មិនសមស្របសម្រាប់អ្នកប្រើប្រាស់ដែលមិនបានទទួលព័ត៌មានអំពីសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ។

(ii). ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់ ។

31. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុរួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។ តម្លៃសមស្រប គឺជាតម្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬបានទូទាត់ ដើម្បីផ្ទេរបំណុលទៅតាមលំដាប់លំដោយនៅក្នុងប្រតិបត្តិការ រវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងចម្បង ឬប្រសិនបើអវត្តមានទីផ្សារដែលមានការរីកចម្រើនបំផុតដែលធនាគារបានទទួលនៅកាលបរិច្ឆេទនោះ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឱ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ ។

តម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន ហើយអាចរកបាន ត្រូវបានប្រើសម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបាន មិនអាចប្រើប្រាស់បាន នោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដែលមានអត្រាអប្បហារ ការប៉ាន់ស្មាននៃលំហូរទឹកប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

31. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ (ត)

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុ មិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 7 ៖ ការបង្ហាញឧបករណ៍ហិរញ្ញវត្ថុដែលទាមទារឱ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប។ ការបង្ហាញទាំងនោះមានដូចជាការវិនិយោគទៅលើបុត្រសម្ព័ន្ធ និងទ្រព្យ និងបរិក្ខារ។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានដូចជាសាច់ប្រាក់ និងសាច់ប្រាក់សមមូល សមតុល្យនៅធនាគារជាតិ ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗ មិនមានលក្ខណៈជាសារវន្តចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុងទីផ្សារ ដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះ នៅកាលបរិច្ឆេទរាយការណ៍មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ។

តម្លៃសមស្របគឺផ្អែកលើវិធីសាស្រ្ត និងការសន្មតដូចខាងក្រោម៖

ការវិនិយោគ

តម្លៃសមស្របដែលបានប៉ាន់ស្មាន ជាទូទៅគឺផ្អែកលើតម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន ។ នៅពេលមិនមានទីផ្សារដែលមានស្រាប់សម្រាប់មូលបត្រមួយចំនួន នោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានលើទិន្នន័យទីផ្សារប្រហាក់ប្រហែល ឬ ទ្រព្យសកម្មរបីសុទ្ធរបស់វិនិយោគិន ។

ហិរញ្ញប្បទាន បុរេប្រទាន និងផ្សេងៗទៀត

តម្លៃសមស្របត្រូវបានប៉ាន់ស្មាន ដោយការធ្វើអប្បហារលើលំហូរទឹកប្រាក់ដែលបានប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាទីផ្សារនៃការផ្តល់ហិរញ្ញប្បទានដែលមានហានិភ័យឥណទាន និងកាលកំណត់ស្រដៀងគ្នា ។

ចំណាត់ថ្នាក់តម្លៃសមស្រប

ស.រ.ហ.អ.ក 7 បញ្ជាក់ពីចំណាត់ថ្នាក់នៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើ ថាតើទិន្នន័យនៃបច្ចេកទេសវាយតម្លៃទាំងនោះអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ ទិន្នន័យដែលអាចអង្កេតបាន ឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចអង្កេតបានឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់ធនាគារ ។ ចំណាត់ថ្នាក់នៃតម្លៃសមស្របមានដូចខាងក្រោម:

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

31. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ (ត)

ចំណាត់ថ្នាក់តម្លៃសមស្រប (ត)

- កម្រិត 1 - តម្លៃដកស្រង់ (មិនបានធ្វើនិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា ។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងឧបករណ៍បំណុល ។
- កម្រិត 2 - ទិន្នន័យក្រៅពីតម្លៃដែលបានដកស្រង់រាប់បញ្ចូលក្នុងកម្រិត 1 ដែលអាចអង្កេតបានចំពោះទ្រព្យសកម្ម ឬបំណុលដោយផ្ទាល់ (ឧទាហរណ៍ តម្លៃ) ឬដោយប្រយោល (ឧទាហរណ៍ កើតចេញពីតម្លៃ) ។
- កម្រិត 3 - ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ធាតុចូលដែលមិនអាចអង្កេតបាន) ។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍បំណុលដែលមានសមាសធាតុមិនអាចអង្កេតបានជាសារវន្ត ។

តម្លៃយោង និងតម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ធនាគារ មិនបានវាស់វែងនៅតម្លៃសមស្របទេ។ ដោយសារមិនមានតម្លៃទីផ្សារដែលអាចផ្ទៀងផ្ទាត់បាន សម្រាប់ផ្នែកយ៉ាងសំខាន់នៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុនៅតម្លៃសមស្រប ដូចច្នេះការវាស់វែងត្រូវបានធ្វើឡើងដោយផ្អែកទៅលើការប៉ាន់ស្មានរបស់អ្នកគ្រប់គ្រង យោងទៅតាមប្រវត្តិរូបរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ។ តាមមតិរបស់អ្នកគ្រប់គ្រង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ រួមបញ្ចូលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ជាការប៉ាន់ស្មានមានហេតុផលនៃតម្លៃសមស្រប។

32. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗដែលបានបង្ហាញនៅខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់កាលបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ហើយនៅក្នុងការរៀបចំរបាយការណ៍ស្ថានហិរញ្ញវត្ថុតាម ស.រ.ទ.ហ.អ.ក ដំបូង នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ក្នុងគោលបំណងផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក លើកលែងតែមានការបង្ហាញផ្សេងពីនេះ ។

ក. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ខ. ប្រតិបត្តិការរូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។

ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ ដែលជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទរាយការណ៍។ ការចំណេញ ឬការខាតបង់ពីការប្តូររូបិយប័ណ្ណបរទេស គឺជាភាពខុសគ្នារវាងរំលស់ថ្លៃដើមជារូបិយប័ណ្ណមុខងារនៅដើមការិយបរិច្ឆេទ ដែលត្រូវបានធ្វើនិយ័តកម្មសម្រាប់ការប្រាក់ប្រសិទ្ធភាព និងការទូទាត់ក្នុងការិយបរិច្ឆេទ ធៀបនឹងរំលស់ថ្លៃដើម ជារូបិយប័ណ្ណបរទេសដែលបានប្តូរដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទរាយការណ៍ ។

ទ្រព្យសកម្ម និងបំណុលដែលមិនមែនជារូបិយវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមរម្យជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកនៅអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃសមស្របត្រូវបានកំណត់។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងផ្អែកលើតម្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេសត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ ។

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(i). ការទទួលស្គាល់ និងការវាស់វែងដំបូង

ធនាគារទទួលស្គាល់ជាលើកដំបូងនូវឥណទាន និងបុរេប្រទាន ប្រាក់កម្ចី និងអនុបំណុល នៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ ។ ទ្រព្យហិរញ្ញវត្ថុផ្សេងទៀត រួមបញ្ចូលការទិញ និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមធម្មតា ទទួលស្គាល់នៅកាលបរិច្ឆេទពាណិជ្ជកម្ម ដែលជាកាលបរិច្ឆេទដែលធនាគារក្លាយជាភាគីនៃការផ្តល់ឧបករណ៍តាមកិច្ចសន្យានេះ ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប សម្រាប់ឧបករណ៍ដែលតាមធម្មតាមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") បូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ការចាត់ចំណាត់ថ្នាក់

ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែង៖ រំលស់ថ្លៃដើម FVOCI ឬ FVTPL ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") ។

ឧបករណ៍បំណុល ត្រូវបានវាស់វែងនៅ FVOCI លុះត្រាតែវាបានបំពេញនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") ។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ ធនាគារត្រូវតែជ្រើសរើសការបង្ហាញការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើការវិនិយោគនីមួយៗ ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ការចាត់ចំណាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅអ្នកគ្រប់គ្រង ។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រងផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឲ្យស៊ីសង្វាក់គ្នារវាង រយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឲ្យមានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម ។
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅ អំពីរបៀបដែលធ្វើឲ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ ។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ការចាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង ។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ ។

ដើម្បីវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ធនាគារត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលការវាយតម្លៃថាតើ ទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឲ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់ ។

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យាពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃប្រាក់តាមពេលវេលា (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់) ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ព). ការចាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ឥណទានដែលមិនអាចប្រមូលមកវិញបាន

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយធនាគារ ដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជនក៏មានកំហិតធនាគារក្នុងការទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន) ។ ក្នុងករណីនេះ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះអាចប្រមូលមកវិញបានតែប្រាក់ដើម និងការប្រាក់ឬទេ ។ ជាទូទៅធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារក្នុងការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើធនាគារទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ ។

ការចាត់ចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលដែលធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួនក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iii). ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។

បំណុលហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ ។

(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ ។ ក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល (iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមកវិញលើថ្លៃចំណាយប្រតិបត្តិការ ដែលកើតឡើងត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្មនិង

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្មដែលឈប់ទទួលស្គាល់ ។

- ប្រសិនបើលំហូរទឹកប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង ។ ប្រសិនបើ ធនាគារមានគម្រោងកែប្រែ ទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឲ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ ទ្រព្យសកម្មនោះត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយការលុបចេញពីបញ្ជី)។ វិធីសាស្ត្រនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យ ជាទូទៅមិនអាចអនុវត្តបាននោះទេ។
- ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ ដូច្នេះ ធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាត ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ ។
- ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃ នៃទ្រព្យសកម្ម ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

បំណុលហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង ។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប ។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬ ខាត ។ តម្លៃតបស្នងរួមមាន ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុល ហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី ។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឲ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ ។

(v). ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែ ធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ឋ). ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យការមិនអនុវត្តកាតព្វកិច្ច ។

ធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន ។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់ ។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេនោះ ធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន ។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូងជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យឬបានទទួល ។ ប្រសិនបើធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាតផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប មានតម្លៃលក់ និងតម្លៃទិញនោះ ធនាគារវាស់វែងទ្រព្យសកម្ម និងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vi). ការវាស់វែងតម្លៃសមស្រប (ត)

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយធនាគារ តាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទាន ត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមានស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់ ។ ការកែតម្រូវត្រឹមកម្រិតទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទាន ដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋាននៃការកែតម្រូវហានិភ័យដែលពាក់ព័ន្ធ នៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗ នៃទ្រព្យសកម្ម និងបំណុលនោះ ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណ:អាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់ ។

ធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង ។

(vii). ឱនភាពនៃតម្លៃ

ធនាគារទទួលស្គាល់សំវិធានធនលើការរំពឹងទុកលើការខាតបង់ឥណទាន ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានបោះផ្សាយ ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទានពេញអាយុកាល លើកលែងគណនីខាងក្រោម ដែលត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទានរយៈពេល 12ខែ៖

- ការវិនិយោគលើមូលបត្របំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ។

ការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់ឥណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទាន 12ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី 1" ។

ការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល (Life-time ECL) គឺជាការរំពឹងទុកលើការខាតបង់ឥណទាន ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី 2" ។

នៅកាលបរិច្ឆេទនៃរបាយការណ៍ ធនាគារវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ។ នៅពេលដែលហានិភ័យឥណទានកើនឡើជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងអាយុកាលនៃការរំពឹងទុកលើការខាតបង់ឥណទាន ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មានលើការរំពឹងទុកលើការខាតបង់ឥណទាន នោះធនាគារពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រ ដែលពាក់ព័ន្ធ និងអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់ ។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគ ដោយផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃឥណទាន ព្រមទាំងបញ្ចូលព័ត៌មានប្រមើលអនាគត ។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលបណ្តាលឲ្យគ្មានការកើនឡើងជាសារវន្តនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានលើការរំពឹងទុកលើការខាតបង់ឥណទានគឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារប្រឈមនឹងហានិភ័យឥណទាន ។

ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន

ធនាគារវាយតម្លៃថាតើមានហានិភ័យឥណទានបានកើនឡើងជាសារវន្ត ឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូង នៅកាលបរិច្ឆេទរាយការណ៍ ។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានផ្អែកជាសំខាន់លើចរិតលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ ។

ធនាគារពិចារណាថាការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត កើតឡើងនៅពេលទ្រព្យសកម្មមានការខកខានសងមិនតិចជាងរយៈពេលចំនួន 30 ថ្ងៃ ។ ចំនួនថ្ងៃខកខានសងត្រូវបានកំណត់ដោយការរាប់ចំនួនថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ ដែលការបង់សងទាំងអស់មិនទាន់បានទទួល ។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អតិថិជនឡើយ ។

ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មិនមានការកើនឡើងលើហានិភ័យឥណទានជាសារវន្ត ទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេនោះ សំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

និយមន័យនៃការខកខានសង

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- ធនាគារពិចារណាថាការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន កើតឡើងមិនលើសពីពេលដែលទ្រព្យសកម្មហួសកាលកំណត់សងស្មើ ឬលើសពី 30 ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង ឬច្រើនជាងឬស្មើ 15 ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី ។

ការវាស់វែងលើការពឹងទុកលើការខាតបង់ឥណទាន

ការរំពឹងទុកលើការខាតបង់ឥណទាន គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យមនៃការបាត់បង់ឥណទាន ។ ការរំពឹងទុកលើការខាតបង់ឥណទាន ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរទឹកប្រាក់ដែលជំពាក់ធនាគារស្របតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន) ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត ។
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលជំពាក់ធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរទឹកប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន ប្រសិនបើឥណទានត្រូវបានដកប្រើ ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង ("PD")
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង ("LGD") និង
- ទំហំនៃការខកខានសង ("EAD")

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី 1 ត្រូវបានគណនាដោយផលគុណនៃ PD 12 ខែ នឹង LGD នឹង EAD ។ ECL ពេញអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹង LGD នឹង EAD ។

គំរូស្ថិតិត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបាន រួចបង្កើតនូវការប៉ាន់ស្មាន PD ពេញអាយុកាលដែលនៅសល់ និងថាតើសមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ ។

LGD គឺជាតវិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការខកខានសង ។ ធនាគារប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង ។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធអាទិភាពនៃការទាមទារសំណង វិស័យដែលអតិថិជនស្ថិតនៅ ចំណាយលើការប្រមូលពីទ្រព្យបញ្ចាំដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ។ សម្រាប់ឥណទានដែលការពារដោយទ្រព្យអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ ("LTV") គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD ។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នា ហើយសម្រាប់ឥណទានគេហដ្ឋាន គឺអាស្រ័យលើការប្រែប្រួលតម្លៃអចលនទ្រព្យ ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហារ ដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធភាព ។

EAD តំណាងឲ្យតម្លៃសមតុល្យនៅពេលមានការខកខានសង ។ ធនាគារទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាម កិច្ចសន្យា និងកើតចេញពីការបង់រំលស់ ។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺតម្លៃយោងដុលនៅពេលមានការខកខានសង ។ សម្រាប់កាតព្វកិច្ចឲ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ (ត)

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12 ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី1 ធនាគារវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យាប្រសិនបើមាន) ដែលមានហានិភ័យលើឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ ធនាគារពិចារណាលើរយៈពេលដែលវែងជាង ។ រយៈពេលដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលធនាគារមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញមិននាំឲ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់ ។
- ប្រសិនបើការរៀបចំឡើងវិញ នាំឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់ ។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី 3")។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុក នៃទ្រព្យសកម្មហិរញ្ញវត្ថុ ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឲ្យមានឱនភាពនៃតម្លៃ ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង 90 ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ ។

ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធននៃការខាតបង់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម ដោយធ្វើការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ (ត)

ការលុបចោល

ឥណទានផ្តល់ដល់អតិថិជនត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរទឹកប្រាក់គ្រប់គ្រាន់ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់សុទ្ធពីឱនភាពនៃតម្លៃ ឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងចំណេញ ឬខាត និង OCI ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឲ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ធនាគារក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់ ។

ឃ. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសានុនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

ង. ដើមទុន

(i). ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន ។ ថ្លៃដើមផ្ទាល់ក្នុងការបញ្ចេញភាគហ៊ុន ត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធន បន្ទាប់ពីដកពន្ធរួច ។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬបំណុលផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ ។ ការបែងចែកទៅឲ្យអ្នកកាន់ឧបករណ៍ហិរញ្ញវត្ថុត្រូវបានចាត់ទុកជាឧបករណ៍មូលធនមួយ ដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ង. ដើមទុន (ត)

(i). ដើមទុនផ្សេងៗ

ដើមទុនផ្សេងៗត្រូវបានចែងថ្នាក់ជាមូលធន ។ យោងតាមលិខិតលេខ 536 ចុះថ្ងៃទី 3 ខែ កុម្ភៈ ឆ្នាំ 2016 ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ជូននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានបន្ថែមជាមួយនឹងចំណារពន្យល់របស់ខ្លួនដែលបានចុះនៅថ្ងៃទី 4 ខែ កុម្ភៈ ឆ្នាំ 2016 ធនាគារអភិវឌ្ឍន៍ជនបទត្រូវបានផ្តល់ការយល់ព្រមតាមសំណើរអោយចាត់វិធានការទៅលើឥណទានមិនដំណើរការចំនួន 18,269,567 ដុល្លារអាមេរិក និងត្រូវបានដកចេញពីភាគហ៊ុនដោយដកចេញពីតារាងតុល្យការ និងត្រួតពិនិត្យដោយឡែក ។ ការទទួលបានមកវិញបន្ទាប់នៃឥណទាននិងបុរេប្រទានទាំងនោះនឹងទទួលស្គាល់នៅក្នុងគណនីដើមទុនផ្សេងៗទៀតរបស់ធនាគារ បន្ទាប់ពីការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

ច. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតសម្រាប់ភាពខុសគ្នារវាងសំវិធានធនស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី 1 ខែ ធ្នូ ឆ្នាំ 2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ឆ.ណ ចុះថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2018 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ ស្របតាមប្រការ 73 គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 ជាមួយនឹងសំវិធានធនដែលគណនាតាមប្រការ 72 និងត្រូវកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ គណនាតាមប្រការ 72 មានលទ្ធផលទាបជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាម ស.រ.ទ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ គណនាតាមប្រការ 72 មានលទ្ធផលខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ទ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

ទុនបម្រុងតាមបទប្បញ្ញត្តិ មិនត្រូវបានដាក់បញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ស្ថាប័នធនាគារឡើយ ។

32. **គោលនយោបាយគណនេយ្យសំខាន់ៗ (ត)**

ឆ. ប្រាក់បញ្ញើនៅធនាគារនានា

ប្រាក់បញ្ញើនៅធនាគារនានា ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដកឱនភាពនៃតម្លៃដែលមិនអាចប្រមូលមកវិញបាន ។

ជ. ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

ឈ. ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ។

ញ. ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងទៀតត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធិភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

ដ. ទ្រព្យ និងបរិក្ខារ

(i). ការទទួលស្គាល់ និងការវាស់វែង

ផ្នែកនៃទ្រព្យ និងបរិក្ខារត្រូវបានវាស់វែងតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃ បង្គរ ។

ចំណាយថ្លៃដើមរួមបញ្ចូលទាំងការចំណាយដោយផ្ទាល់ទៅលើការទិញទ្រព្យ និងការចំណាយដោយផ្ទាល់ផ្សេងៗទៀត ក្នុងការនាំយកទ្រព្យសកម្មទៅក្នុងលក្ខខណ្ឌដែលអាចប្រើប្រាស់ដែលបានគ្រោងទុក និងថ្លៃដើមនៃការរុះរើ និងផ្លាស់ប្តូរទីកន្លែង និងការស្តារទីតាំងដែលពួកគេស្ថិតនៅ ។ ថ្លៃដើមនៃទ្រព្យដែលបានសាងសង់ដោយខ្លួនឯង ត្រូវរួមបញ្ចូលទាំងថ្លៃដើមសម្ភារៈ និងកម្លាំងពលកម្មផ្ទាល់ផងដែរ ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ ការចំណាយលើប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្មស្របតាមគោលនយោបាយគណនេយ្យលើថ្លៃដើមប្រាក់កម្ចី ។ ថ្លៃដើមក៏អាចរួមបញ្ចូលទាំងការផ្ទេរមូលធន ដែលជាចំណេញ ឬ ខាតណាមួយផងដែរ លើការការពារហានិភ័យលំហូរសាច់ប្រាក់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះរូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យ និងបរិក្ខារ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ដ. ទ្រព្យ និងបរិក្ខារ (ត)

(i). ការទទួលស្គាល់ និងការវាស់វែង

ការទិញសូហ្វវែរដែលមានសារៈសំខាន់ដែលទាក់ទងទៅនឹងមុខងារឧបករណ៍ក៏ត្រូវបានចាត់ទុកជាផ្នែកមួយនៃបរិក្ខារផងដែរ ។

ប្រសិនបើផ្នែកជាសារវន្តណាមួយនៃទ្រព្យ និងបរិក្ខារទាំងនោះ មានអាយុកាលប្រើប្រាស់ខុសពីគ្នា ផ្នែកទាំងនោះត្រូវបានដាក់ជាផ្នែកដោយឡែក (សមាសភាពចម្បង) នៃទ្រព្យ និងបរិក្ខារ ។

(ii). ចំណាយបន្ទាប់

ចំណេញ ឬខាតពីការលក់នៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជា "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងៗ" នៅក្នុងចំណេញ ឬខាត ។

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយផ្នែកនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ធនាគារ ហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពអាចជឿជាក់បាន ។ តម្លៃយោងនៃធាតុដែលបានជំនួសនោះ ត្រូវឈប់ទទួលស្គាល់ជាចំណេញ ឬខាត ។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍លទ្ធផលក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iii). រំលស់

ថ្លៃដើមនៃរបស់ធាតុនៃទ្រព្យ និង បរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងតម្លៃយោងនៃធាតុនោះប្រសិនបើវាអាចមានផលចំណេញសេដ្ឋកិច្ចនាពេលអនាគត ដែលភាពចំណេញនឹងហូរចូលធនាគារ ហើយការចំណាយរបស់វាអាចត្រូវបានវាស់វែងបាន ។ តំលៃយោងរបស់ធាតុនៃទ្រព្យ និង បរិក្ខារ នឹងត្រូវបានទទួលស្គាល់ក្នុងរបាយកាណ៍ចំណេញ ឬ ខាត ។ ថ្លៃដើមនៃការប្រើប្រាស់ទ្រព្យ និង បរិក្ខាប្រចាំថ្ងៃត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬខាត ដែលបានកើតឡើងជាប្រចាំ។

រំលស់ គឺផ្អែកទៅលើថ្លៃដើមនៃទ្រព្យសកម្ម ដកតម្លៃសំណល់របស់វា ។ សមាសធាតុសំខាន់ៗនៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃ ហើយប្រសិនបើសមាសធាតុមួយមានអាយុកាលប្រើប្រាស់ខុសគ្នាពីទ្រព្យសកម្មដែលនៅសល់ សមាសធាតុនោះត្រូវបានធ្វើឡើងដាច់ដោយឡែក ។

រំលស់ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាតលើតាមមូលដ្ឋានរំលស់ថយចុះលើកលែងតែអគារ និងការកែលម្អអគារដែលត្រូវបានរំលស់តាមមូលដ្ឋានរំលស់ថេរ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ដ. ទ្រព្យ និងបរិក្ខារ (ត)

(iii). រំលស់(ត)

រំលស់ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យ និងបរិក្ខារត្រូវបានតម្លើង និងអាចប្រើប្រាស់បាន ឬ ទ្រព្យសកម្មដែលបានសាងសង់ ចាប់ពីការិយបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានបញ្ចប់ និងអាចប្រើប្រាស់បាន។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នមានដូចខាងក្រោម៖

	អត្រា
អគារ	5%
ការកែលម្អអគារ	10%
យានយន្ត	12.5%
បរិក្ខារកុំព្យូទ័រ	25%
បរិក្ខារការិយាល័យនិងសង្ហារឹម	12.5%

ដីធ្លីមិនត្រូវបានគេធ្វើរំលស់នោះទេ ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងធ្វើនិយ័តភាពប្រសិនបើសមស្រប ។

ឋ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាប័ណ្ណសូហ្វវែរកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ សូហ្វវែរកុំព្យូទ័រ ដែលបានទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញសូហ្វវែរជាក់លាក់នោះមកប្រើប្រាស់ ។

ទ្រព្យសកម្មអរូបីត្រូវបានរំលស់តាមវិធីសាស្ត្ររំលស់ថយចុះនៅអត្រា20%ក្នុង 1 ឆ្នាំ ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកុំព្យូទ័រសូហ្វវែរ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង ។

ទ្រព្យសកម្មអរូបីកំពុងដំណើរការគឺជាការទូទាត់សម្រាប់ការតម្លើងកុំព្យូទ័រសូហ្វវែរនិងប្រព័ន្ធ។ ទ្រព្យសកម្មអរូបីកំពុងដំណើរការត្រូវបានគេធ្វើរំលស់នៅពេលរួចរាល់ក្នុងការប្រើប្រាស់។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ឌ. ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែងបន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

ឍ. អនុបំណុល

អនុបំណុល ត្រូវបានចាត់ទុកជាផ្នែកមួយនៃបំណុលហិរញ្ញវត្ថុ នៅពេលដែលមានកាតព្វកិច្ចសងតាមកិច្ចសន្យាជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅឲ្យអង្គភាពមួយផ្សេងទៀត ឬដើម្បីផ្តោះប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយផ្សេងទៀតក្រោមលក្ខខណ្ឌ ដែលមិនអំណោយផលចំពោះធនាគារ ហើយប្រសិនបើមិនដូច្នេះទេ វានឹងត្រូវចាត់ទុកជាមូលធន ។ អនុបំណុលដែលបានអនុម័តដោយធនាគារជាតិនៃកម្ពុជា ត្រូវបានរាប់បញ្ចូលទៅក្នុងដើមទុនថ្នាក់ទី 2 ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ។ អនុបំណុល ត្រូវបានបង្ហាញតាមរំលស់ថ្លៃដើម ។

ណ. ទ្រព្យសម្បត្តិរឹបអូស

ទ្រព្យសម្បត្តិដែលបានរឹបអូសរួមមានអចលនវត្ថុនិងចលនវត្ថុដែលត្រូវបានកំណត់តាមថ្លៃដើម ដកការខាតបង់លើឱនភាពតម្លៃបង្គរប្រសិនបើមាន ។

ត. សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញប្បទាន ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ថ. ការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឲ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់ថ្លៃដើមរបស់បំណុលហិរញ្ញវត្ថុ ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃនៅពេលទិញ ធនាគារធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានដែលរំពឹងទុកនោះទេ (ECL) ។ សម្រាប់ទ្រព្យសកម្មដែលទិញ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញ អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនាដោយប្រើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតរួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL) ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព ។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ។

រំលស់ថ្លៃដើម និងតម្លៃយោងដុល

រំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់សងប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ (ឬ ឱនភាពនៃតម្លៃមុនថ្ងៃទី 1 ខែ មករា ឆ្នាំ 2018) ។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. **គោលនយោបាយគណនេយ្យសំខាន់ៗ (ត)**

ថ. ការប្រាក់ (ត)

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើមនៃបំណុល ។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្របនៃឧបករណ៍ការពារ នៅកាលបរិច្ឆេទដែលរំលស់ត្រូវបានចាប់ផ្តើមកែតម្រូវ ។

ទោះជាយ៉ាងណាក៏ដោយ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ ។

ការបង្ហាញ

ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និង លទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម ។

ចំណាយការប្រាក់ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមរំលស់ថ្លៃដើម ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ទ. កម្រៃ និងជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព ។

ចំណូលកម្រៃ និងជើងសាផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម ។

កិច្ចសន្យាជាមួយអតិថិជនដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចមានវិសាលភាពដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 9 និងដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 15 ។ ក្នុងករណីនេះ ជាដំបូងធនាគារត្រូវអនុវត្ត ស.រ.ហ.អ.ក 9 ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 9 ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក 15 ចំពោះផ្នែកដែលនៅសេសសល់ ។

ធ. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ ក្រៅពីពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់ការិយបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ឬទេ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង ។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បាន តម្លៃដែលអាចប្រមូលមកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ធំជាងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន ។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់ ។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។ ការខាតបង់លើឱនភាពនៃតម្លៃនៃឯកតាបង្កើតសាច់ប្រាក់ ត្រូវបានបែងចែកដោយកាត់បន្ថយតម្លៃយោងនៃតម្លៃកេរ្តិ៍ឈ្មោះរបស់ឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) ជាមុន ហើយបន្ទាប់មកដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មដទៃទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) លើមូលដ្ឋានសមាមាត្រ ។

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ធ. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

ការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ក្នុងពេលកន្លងផុតទៅ ត្រូវបានប៉ាន់ប្រមាណរាល់កាលបរិច្ឆេទនៃការរាយការណ៍ ថាតើមានសញ្ញាណណាមួយដែលការខាតបង់បានថយចុះ ឬលែងមានការខាតបង់តទៅទៀត ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញ ប្រសិនបើមានការប្រែប្រួលតម្លៃប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃដែលអាចប្រមូលមកវិញបាន ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឲ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ មិនលើសពីតម្លៃយោងដែលត្រូវកំណត់ (ដករំលស់) ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ ។

ន. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាចំណេញឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ ។

ធនាគារបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមបញ្ចូលបំណុលស្រាយពន្ធមិនច្បាស់លាស់ មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយវាត្រូវបានកត់ត្រាក្រោមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 37 *សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព* ហើយត្រូវបានទទួលស្គាល់ថាជាការចំណាយដែលពាក់ព័ន្ធ "ការចំណាយផ្សេងទៀត" ។

(i) ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ ឬទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

(ii) ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

32. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ii) ពន្ធពន្យារ (ត)

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍ ។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងនូវពន្ធដែលធនាគាររំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ ។

ប. បំណុលយថាភាព

ក្នុងករណីដែលមិនតម្រូវឲ្យមានការហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ ហើយវាត្រូវបានបង្ហាញថាជាបំណុលយថាភាព លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្មើតែគ្មាន ។ កាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែ អត្ថិភាពនៃកាតព្វកិច្ច នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគត មួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាបំណុលយថាភាពដែលអាចកើតមានឡើង លុះត្រាតែប្រូបាប៊ីលីតេនៃការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្មើតែគ្មាន ។

ផ. ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានចំនួននោះត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាពក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចស្មើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាពដែលអាចកើតឡើង លុះត្រាតែប្រូបាប៊ីលីតេនៃការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចស្មើរតែគ្មាន ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប

ក. ការស្តារឡើងវិញ

ក្នុងអំឡុងពេលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 អ្នកគ្រប់គ្រងរបស់ធនាគារ បានរកឃើញនូវកំហុសមួយចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុកន្លងមក ដែលបានបង្ហាញមិនត្រឹមត្រូវ ។ កំហុសទាំងនោះមានដូចជា៖

i. មូលធន និងមូលធនផ្សេងៗមិនបានចាត់ថ្នាក់ត្រឹមត្រូវចំនួន 21,541,889 ដុល្លារអាមេរិក និង 24,468,809 ដុល្លារអាមេរិក នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និង ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 នៅពេលដែលលក្ខន្តិកៈត្រូវបានផ្លាស់ប្តូរតាំងពីឆ្នាំ 2016 ។

ii. ធនាគារបានកត់ត្រាមិនត្រឹមត្រូវនូវការប្រាក់ព្យួរទុកចំនួន 2,295,326 ដុល្លារអាមេរិក និង1,390,008 ដុល្លារអាមេរិក នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដែលជាលទ្ធផលធ្វើឲ្យចំណូលពីការប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 បង្ហាញលើសចំនួន 905,318 ដុល្លារអាមេរិក ។

iii. ដោយសារតែប្រព័ន្ធឥណទានរបស់ធនាគារមានកម្រិត បញ្ជីចំនួនថ្ងៃហួសកំណត់ (DPD) និងតារាងនៃឥណទាន និងបុរេប្រទានដែលត្រូវបានទាញយកមិនត្រឹមត្រូវនោះទេ ។ ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនសុទ្ធបានបង្ហាញលើសចំនួន 7,946,374 ដុល្លារអាមេរិកនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងចំនួន 10,009,910 ដុល្លារអាមេរិកនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។ ការបង្ហាញលើសទាំងនេះ មានផលប៉ះពាល់ដល់សំវិធានធនក្រោមស្តង់ដាពីមុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ចំនួន 2,063,536 ដុល្លារអាមេរិក ។

ចំនុច (ii) និង(iii) ធ្វើឲ្យមានផលប៉ះពាល់ដល់ប្រាក់ចំណេញរក្សាទុកចំនួន 10,241,700 ដុល្លារអាមេរិកនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និង 11,399,918 ដុល្លារអាមេរិក នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

អ្នកគ្រប់គ្រងធនាគារ បានសម្រេចចិត្តធ្វើការស្តារឡើងវិញនូវព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និង នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ទៅលើកំហុសឆ្គងទាំងអស់នេះ ។

ធនាគារ អភិវឌ្ឍន៍ជនបទ
(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប (ត)

ខ. ការពន្យល់អំពីការផ្លាស់ប្តូរទៅស្តង់ដារ ស.រ.ទ.ហ.អ.ក

ការអនុវត្តក្របខណ្ឌស្តង់ដារ ស.រ.ទ.ហ.អ.ក

ធនាគារបានអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ដែលចេញដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ។ របាយការណ៍ហិរញ្ញវត្ថុនេះ ជារបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងស្របតាម ស.រ.ទ.ហ.អ.ក រួមទាំងការអនុវត្ត ស.រ.ហ.អ.ក 1 *ការអនុវត្តជាលើកដំបូងស.រ.ទ.ហ.អ.ក*។

ហេតុដូច្នេះ ធនាគារបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម ស.រ.ទ.ហ.អ.ក ដែលមានប្រសិទ្ធិភាពអនុវត្តសម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬនៅក្រោយថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019រួមជាមួយនឹងព័ត៌មានប្រៀបធៀប នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដូចដែលបានរៀបរាប់នៅក្នុងគោលនយោបាយគណនេយ្យសំខាន់ៗ នៅក្នុងកំណត់សម្គាល់ 32 ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងដំបូង នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដែលជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក ។ និយ័តភាពសំខាន់ៗ ដែលបានធ្វើឡើងដោយធនាគារក្នុងការកត់ត្រាឡើងវិញនូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 និងរបាយការណ៍ហិរញ្ញវត្ថុដែលបានបោះផ្សាយពីមុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដែលរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហៅកាត់ថា ("ស្តង់ដារពីមុន") ត្រូវបានបង្ហាញដូចខាងក្រោម ។

ការអនុវត្តការលើកលែងដែលអាចជ្រើសរើសបាន

ស.រ.ហ.អ.ក 1 អនុញ្ញាតឲ្យអ្នកអនុវត្តជាលើកដំបូង នូវការលើកលែងមួយចំនួនពីការអនុវត្តតាមវិធីសាស្ត្រប្រតិសកម្ម នូវតម្រូវការ ស.រ.ហ.អ.ក ។ ធនាគារបានអនុវត្តការលើកលែងដូចខាងក្រោម៖

តម្លៃសមស្រប ឬការវាយតម្លៃឡើងវិញដោយចាត់ទុកជាថ្លៃដើម - ទ្រព្យ និងបរិក្ខារ

ធនាគារបានជ្រើសរើសដើម្បីវាស់វែងធាតុនីមួយៗ នៃទ្រព្យ និងបរិក្ខារ ដោយប្រើប្រាស់ស្តង់ដារពីមុន ដែលអាចប្រៀបធៀបបានទៅនឹងតម្លៃដើមដករំលស់ ស្របតាម ស.រ.ទ.ហ.អ.ក នៅការិយបរិច្ឆេទផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក ។

33. ព័ត៌មានប្រៀបធៀប (ត)

ខ. ការពន្យល់អំពីការផ្លាស់ប្តូរទៅស្តង់ដារ ស.រ.ទ.ហ.អ.ក (ត)

ការលើកលែងដែលមិនអាចជ្រើសរើសបាន

ការប៉ាន់ស្មាន

ការប៉ាន់ស្មាននៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 និងនៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 គឺស្របគ្នានឹងការប៉ាន់ស្មានដែលមានការិយបរិច្ឆេទដូចគ្នាដោយស្របតាមស្តង់ដារពីមុន ។ ការប៉ាន់ស្មានដែលធនាគារបានប្រើដើម្បីបង្ហាញចំនួនទឹកប្រាក់ទាំងនេះដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក គឺឆ្លុះបញ្ចាំងពីលក្ខខណ្ឌដែលមាននៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដែលជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក និងនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ។

ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

អ្នកអនុវត្តជាលើកដំបូង ត្រូវតែអនុវត្តការឈប់ទទួលស្គាល់តាមតម្រូវការរបស់ ស.រ.ទ.ហ.អ.ក សម្រាប់ប្រតិបត្តិការដែលបានកើតឡើងនៅថ្ងៃ ឬនៅក្រោយថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក តាមវិធីសាស្ត្រទស្សនវិស័យ ។ ទោះជាយ៉ាងណាក៏ដោយ អង្គភាពមួយអាចអនុវត្តការឈប់ទទួលស្គាល់តាមតម្រូវការរបស់ ស.រ.ទ.ហ.អ.ក ចាប់ពីការិយបរិច្ឆេទប្រតិសកម្ម ដែលអង្គភាពបានជ្រើសរើស ប្រសិនបើ ព័ត៌មានដែលតម្រូវឲ្យធ្វើបែបនេះ គឺទទួលបាននៅពេលចាប់ផ្តើមធ្វើប្រតិបត្តិការគណនេយ្យទាំងនោះ ។

ធនាគារបានអនុវត្តតាមតម្រូវការនៃការឈប់ទទួលស្គាល់របស់ ស.រ.ទ.ហ.អ.ក តាមវិធីសាស្ត្រទស្សនវិស័យ សម្រាប់ប្រតិបត្តិការដែលកើតឡើងនៅថ្ងៃ ឬនៅក្រោយថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

ការផ្ទៀងផ្ទាត់រួមមានជួរឈរពីរសម្រាប់ការិយបរិច្ឆេទនីមួយៗ ក៏ដូចជាលទ្ធផលនៃស្តង់ដារពីមុន និង ស.រ.ទ.ហ.អ.ក ។ ជួរឈរនៃ "ការធ្វើចំណាត់ថ្នាក់ឡើងវិញ" រួមមានការធ្វើចំណាត់ថ្នាក់ឡើងវិញ និងការវិភាគចំនួនទឹកប្រាក់ឡើងវិញ តាមស្តង់ដារពីមុន និង ស.រ.ទ.ហ.អ.ក សម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។ ជួរឈរនៃ "ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក" បានបង្ហាញពីផលប៉ះពាល់នៃការផ្លាស់ប្តូរការទទួលស្គាល់ និងការវាស់វែងដែលតម្រូវដោយការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក" ។ ជួរឈរនៃ "ផលប៉ះពាល់ពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក" ត្រូវបានវិភាគបន្ថែមទៀតលើប្រភេទនៃនិយ័តភាព ។

ការពន្យល់ពីរបៀបនៃការផ្លាស់ប្តូរពីស្តង់ដារពីមុន ទៅ ស.រ.ទ.ហ.អ.ក និងការអនុវត្ត ស.រ.ហ.អ.ក 9 និង ស.រ.ហ.អ.ក 15 និង ស.រ.ហ.អ.ក 16 បានជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ ត្រូវបានកំណត់ដោយការសង្ខេបពីបរិមាណនៃការប៉ះពាល់ និងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ។

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ការស្តារឡើងវិញនៃទ្រព្យសម្បត្តិហិរញ្ញវត្ថុ

ផលប៉ះពាល់ពីការផ្លាស់ប្តូរដែលត្រូវបានសង្ខេបដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដុល្លារអាមេរិក
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ		
ទ្រព្យសកម្មផ្សេងៗ	(2,295,326)	(1,390,008)
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន-សុទ្ធ	(7,946,374)	(10,009,910)
ដើមទុន	21,541,889	24,468,809
ដើមទុនផ្សេងៗ	(21,541,889)	(24,468,809)
ប្រាក់ចំណេញរក្សាទុក	10,241,700	11,399,918

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក
របាយការណ៍ចំណេញ ឬ ខាត និងលទ្ធផលលម្អិតផ្សេងៗ	
ចំណូលពីការប្រាក់	905,318
ឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	(2,063,536)
ប្រាក់ចំណេញមុនដកពន្ធ	(1,158,218)
របាយការណ៍លំហូរទឹកប្រាក់	
ប្រាក់ចំណេញមុនដកពន្ធ	(1,158,218)

33. ព័ត៌មានប្រៀបធៀប (ត)

ការផ្ទៀងផ្ទាត់មូលធន

ការផ្ទៀងផ្ទាត់ខាងក្រោមនេះ សង្ខេបពីផលប៉ះពាល់នៃការអនុវត្តដំបូង ស.រ.ទ.ហ.អ.ក ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ។

		ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018				ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			
			ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក				ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក		
	កំណត់សម្គាល់	ស្តង់ដាពីមុន ដុល្លារអាមេរិក	ការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក	ស្តង់ដាពីមុន ដុល្លារអាមេរិក	ការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក
ទ្រព្យសកម្ម									
សាច់ប្រាក់ក្នុងដៃ	គ	2,181,446	(2,181,446)	-	-	1,767,588	(1,767,588)	-	-
សមតុល្យជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា	ក(i), គ	5,015,713	(5,015,713)	-	-	901,239	(901,239)	-	-
សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា	ក(i), គ	29,570,190	(29,570,190)	-	-	14,568,845	(14,568,845)	-	-
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	ក(i), គ	-	35,083,748	-	35,083,748	-	15,396,610	-	15,396,610
ប្រាក់តម្កល់តាមច្បាប់	គ	-	1,645,274	-	1,645,274	-	1,843,886	-	1,843,886
ឥណទាន និងបុរេប្រទានផ្តល់ដល់ អតិថិជន - សុទ្ធ	ក(i), ក(ii), គ	117,301,679	1,253,207	577,677	119,132,563	152,810,766	2,091,480	(395,823)	154,506,423
ទ្រព្យសម្បត្តិរឹបអូស		1,158,384	-	-	1,158,384	2,875,934	-	-	2,875,934
ទ្រព្យសកម្មផ្សេងៗ	គ	1,332,772	(1,214,880)	-	117,892	2,472,939	(2,094,304)	-	378,635
ទ្រព្យ និងបរិក្ខារ		956,392	-	-	956,392	2,872,030	-	-	2,872,030
ទ្រព្យសកម្មអរូបី		18,785	-	-	18,785	11,964	-	-	11,964
ទ្រព្យសកម្មសរុប		157,535,361	-	577,677	158,113,038	178,281,305	-	(395,823)	177,885,482
ទ្រព្យសកម្មសរុប (ពាន់រៀល – កំណត់សម្គាល់ 5)		635,970,252	-	2,332,083	638,302,335	716,334,283	-	(1,590,417)	714,743,867

33. ព័ត៌មានប្រៀបធៀប (ត)

ការផ្ទៀងផ្ទាត់មូលធន (ត)

		ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018				ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			
			ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក				ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក		
	កំណត់សម្គាល់	ស្តង់ដារពីមុន ដុល្លារអាមេរិក	ការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក	ស្តង់ដារពីមុន ដុល្លារអាមេរិក	ការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក
បំណុល និងមូលធន									
ប្រាក់បញ្ញើរបស់អតិថិជន	ក(i)	2,310,999	14,114	-	2,325,113	3,446,575	19,050	-	3,465,625
ប្រាក់បញ្ញើរបស់ធនាគារនានា	ក(i)	50,462	-	-	50,462	24,769	-	-	24,769
ប្រាក់កម្ចី	ខ	111,758,308	946,017	-	112,704,325	125,844,097	1,459,894	-	127,303,991
អនុបំណុល		1,044,084	-	-	1,044,084	1,044,084	-	-	1,044,084
បំណុលផ្សេងៗ	ក(i)	1,518,773	(960,131)	-	558,642	3,718,082	(1,478,944)	-	2,239,138
បំណុលជាពន្ធពន្យា		-	-	1,904,939	1,904,939	-	-	1,391,447	1,391,447
បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ		137,647	-	-	137,647	661,185	-	-	661,185
បំណុលសរុប		116,820,273	-	1,904,939	118,725,212	134,738,792	-	1,391,447	136,130,239
មូលធន									
ដើមទុន		22,035,837	24,468,809	-	46,504,646	24,962,757	21,541,889	-	46,504,646
ដើមទុនផ្សេងៗ		10,700,928	(24,468,809)	-	(13,767,881)	7,955,048	(21,541,889)	-	(13,586,841)
ដើមទុនបម្រុង		816,974	-	-	816,974	899,072	-	-	899,072
ទុនបម្រុងតាមបទប្បញ្ញត្តិ		-	-	11,220,150	11,220,150	-	-	8,919,414	8,919,414
ប្រាក់ចំណេញរក្សាទុក/ប្រាក់ខាតបង្គរ	ក(ii)	7,161,349	-	(12,547,412)	(5,386,063)	9,725,636	-	(10,706,684)	(981,048)
មូលធនសរុប		40,715,088	-	(1,327,262)	39,387,826	43,542,513	-	(1,787,270)	41,755,243
បំណុល និងមូលធនសរុប		157,535,361	-	577,677	158,113,038	178,281,305	-	(395,823)	177,885,482
បំណុលនិងមូលធនសរុប(ពាន់រៀល–កំណត់សម្គាល់ 5)		635,970,252	-	2,332,083	638,302,335	716,334,283	-	(1,590,417)	714,743,867

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប (ត)

ការផ្ទៀងផ្ទាត់របាយការណ៍ចំណេញ ឬ ខាត និងលទ្ធផលលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

			ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក		
	កំណត់សម្គាល់	ស្តង់ដារពីមុន ដុល្លារអាមេរិក	កាចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក
ចំណូលប្រតិបត្តិការ					
ចំណូលពីការប្រាក់	ក(iii)	8,317,964	277,354	-	8,595,318
ចំណាយលើការប្រាក់	ខ	(619,100)	-	-	(619,100)
ចំណូលការប្រាក់សុទ្ធ		7,698,864	277,354	-	7,976,218
ចំណូលផ្សេងៗ		1,073,187	(1,054,800)	-	18,387
ចំណូលប្រតិបត្តិការសរុប		8,772,051	(777,446)	-	7,994,605
ចំណាយលើបុគ្គលិក		(1,883,439)	173,211	-	(1,710,228)
ចំណាយប្រតិបត្តិការផ្សេងៗ	ខ	(1,999,610)	(173,163)	-	(2,172,773)
ចំណាយប្រតិបត្តិការសរុប		(3,883,049)	48	-	(3,883,001)
ចំណេញប្រតិបត្តិការមុនដកសំវិធានធន		4,889,002	(777,398)	-	4,111,604
សំវិធានធនការខាតបង់លើឧបករណ៍ហិរញ្ញវត្ថុ		(1,535,087)	(767,161)	571,059	(1,731,189)
ប្រាក់ចំណេញមុនបង់ពន្ធ		3,353,915	(1,544,559)	571,059	2,380,415
ចំណាយពន្ធលើប្រាក់ចំណេញ		(789,268)	-	513,132	(276,136)
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		2,564,647	(1,544,599)	1,084,191	2,104,279

33. ព័ត៌មានប្រៀបធៀប (ត)

ការសង្ខេបនៃការធ្វើចំណាតថ្នាក់ឡើងវិញនៃប្រាក់ចំណេញ ឬខាត និងលទ្ធផលលំអិតផ្សេងៗ និងការកែសំរួលសំខាន់ៗដែលជាលទ្ធផលនៃការផ្លាស់ប្តូរពីស្តង់ដារពីមុន ទៅ ស.រ.ទ.ហ.អ.ក ។

ការសង្ខេបនៃការធ្វើចំណាតថ្នាក់ឡើងវិញនៃតារាងតុល្យការ និងការកែសំរួលសំខាន់ៗដែលជាលទ្ធផលនៃការផ្លាស់ប្តូរពីស្តង់ដារពីមុន ទៅ ស.រ.ទ.ហ.អ.ក ។

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ស.រ.ហ.អ.ក 9 ឧបករណ៍ហិរញ្ញវត្ថុ បង្ហាញនូវតម្រូវការសម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាមួយចំនួនដើម្បីទិញ ឬលក់ធាតុដែលមិនមែនជាហិរញ្ញវត្ថុ ។ វាក៏ណែនាំផងដែរនូវគំរូថ្មី "ការរំពឹងទុកឥណទានខាតបង់" (ECL) និងគំរូគណនេយ្យការពារហានិភ័យទូទៅថ្មី ។ ធនាគារបានអនុវត្ត ស.រ.ហ.អ.ក 9 ចាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យដែលបណ្តាលមកពីការអនុវត្ត ស.រ.ហ.អ.ក 9 ត្រូវបានអនុវត្តជាទូទៅដោយធនាគារនាពេលក្រោយ លើកលែងតែចំណុចដែលបានពិពណ៌នាខាងក្រោម។

- ការវាយតម្លៃខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកលើដំណើរហេតុ និងកាលៈទេសៈដែលមានស្រាប់នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។
    - ការកំណត់ចំពោះគំរូអាជីវកម្មដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាន់កាប់
    - ការកំណត់ថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ បង្កើតឲ្យមានលំហូរទឹកប្រាក់ដែលជាការទូទាត់សងប្រាក់ដើម និងការប្រាក់ ទៅលើចំនួនទឹកប្រាក់ដែលនៅសល់
    - ការកំណត់នូវការវិនិយោគមូលធន ដែលមិនសម្រាប់យកមកធ្វើការជួញដូរជា FVOCI និង
- ប្រសិនបើការវិនិយោគបំណុលមានហានិភ័យឥណទានទាបនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ធនាគារបានសន្មតថាហានិភ័យឥណទានលើទ្រព្យសកម្មមិនមានការកើនឡើងជាសារវន្តទេ ចាប់តាំងពីការទទួលស្គាល់ដំបូង ។

ផលប៉ះពាល់ដែលកើតឡើងពីការអនុវត្ត ស.រ.ហ.អ.ក 9 រួមទាំងផលប៉ះពាល់លើពន្ធត្រូវបានពិពណ៌នាដូចខាងក្រោម ។

33. ព័ត៌មានប្រៀបធៀប (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(i). ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ក្រោម ស.រ.ហ.អ.ក 9 ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមប្រភេទដូចខាងក្រោម៖ វាស់វែងតាមរំលស់ថ្លៃដើម FVOCI - ឧបករណ៍បំណុល, FVOCI - ឧបករណ៍មូលធន; ឬ FVTPL ។ ការចាត់ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុក្រោម ស.រ.ហ.អ.ក 9 ដែលជាទូទៅគឺផ្អែកលើគំរូអាជីវកម្មដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រង និងលក្ខណៈនៃលំហូរទឹកប្រាក់តាមកិច្ចសន្យា ។

សម្រាប់ការពន្យល់អំពីវិធីដែលធនាគារធ្វើការចាត់ថ្នាក់ និងវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ និងចំណេញនិងខាតដែលពាក់ព័ន្ធក្រោម ស.រ.ហ.អ.ក 9 សូមមើលកំណត់សម្គាល់ 32គ (ii) ។

តារាងខាងក្រោម និងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយខាងក្រោមពន្យល់ពីប្រភេទនៃការវាស់វែងដំបូងនៅក្រោមស្តង់ដារពីមុន និងប្រភេទប្រភេទនៃការវាស់វែងថ្មីក្រោម ស.រ.ហ.អ.ក 9 សម្រាប់ថ្នាក់នីមួយៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(i). ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

	កំណត់សម្គាល់	ការធ្វើចំណាត់ថ្នាក់ដំបូងក្រោមស្តង់ដារពីមុន	ការធ្វើចំណាត់ថ្នាក់ថ្មីក្រោម ស.រ.ហ.អ.ក 9	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
				តម្លៃយោងដំបូងក្រោមស្តង់ដារពីមុន ដុល្លារអាមេរិក	តម្លៃយោងថ្មីក្រោម ស.រ.ហ.អ.ក 9 ដុល្លារអាមេរិក	តម្លៃយោងដំបូងក្រោមស្តង់ដារពីមុន ដុល្លារអាមេរិក	តម្លៃយោងថ្មីក្រោម ស.រ.ហ.អ.ក 9 ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ							
សាច់ប្រាក់ក្នុងដៃ				2,181,446	-	1,767,588	-
សមតុល្យជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា				5,015,713	-	901,239	-
សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា				29,570,190	-	14,568,845	-
សាច់ប្រាក់ និងសាច់ប្រាក់សមមូល (ការធ្វើចំណាត់ថ្នាក់ឡើងវិញ)	(ក)	ថ្លៃដើម	រំលស់ថ្លៃដើម	-	35,083,748	-	15,396,610
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ (ការធ្វើចំណាត់ថ្នាក់ឡើងវិញ)	(ខ)	តម្លៃយោង	រំលស់ថ្លៃដើម	117,301,679	119,132,563	152,810,766	154,506,423
ទ្រព្យសកម្មផ្សេងៗ	(ក)	ថ្លៃដើម	រំលស់ថ្លៃដើម	1,332,772	116,595	2,872,030	377,537
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប				155,401,800	154,332,906	172,920,468	170,280,570
(ពាន់រៀល-កំណត់សម្គាល់ 5)				627,357,067	623,041,942	694,794,440	684,187,330

33. ព័ត៌មានប្រៀបធៀប (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

ា. ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

	កំណត់សម្គាល់	ការធ្វើចំណាត់ថ្នាក់ដំបូងក្រោមស្តង់ដារពីមុន	ការធ្វើចំណាត់ថ្នាក់ថ្មីក្រោម ស.រ.ហ.អ.ក 9	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
				តម្លៃយោងដំបូងក្រោមស្តង់ដារពីមុន ដុល្លារអាមេរិក	តម្លៃយោងថ្មីក្រោម ស.រ.ហ.អ.ក 9 ដុល្លារអាមេរិក	តម្លៃយោងដំបូងក្រោមស្តង់ដារពីមុន ដុល្លារអាមេរិក	តម្លៃយោងថ្មីក្រោម ស.រ.ហ.អ.ក 9 ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើរបស់អតិថិជន	(ត)	ថ្លៃដើម	រំលស់ថ្លៃដើម	2,310,999	2,325,113	3,446,575	3,465,625
ប្រាក់បញ្ញើរបស់ធនាគារនានា	(ត)	ថ្លៃដើម	រំលស់ថ្លៃដើម	50,462	50,462	24,769	24,769
ប្រាក់កម្ចី				111,758,308	112,704,325	125,844,097	127,303,991
អនុបំណុល				1,044,084	1,044,084	1,044,084	1,044,084
បំណុលផ្សេងៗ	(ត)	ថ្លៃដើម	រំលស់ថ្លៃដើម	1,518,773	549,798	3,718,082	2,189,931
បំណុលហិរញ្ញវត្ថុសរុប				116,682,626	116,673,782	134,077,607	134,028,400
បំណុលហិរញ្ញវត្ថុសរុប (ពាន់រៀល - កំណត់សម្គាល់ 5)				471,047,761	471,012,058	538,723,825	538,526,111

33. ព័ត៌មានប្រៀបធៀប(ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(i). ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ក) សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារជាតិនៃកម្ពុជា និងសមតុល្យនៅធនាគារនានា ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់តម្កល់តាមច្បាប់ ហើយដែលពីមុនត្រូវបានធ្វើការវាស់វែងតាមថ្លៃដើម គឺឥឡូវត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ។

(ខ) ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដែលត្រូវបានចាត់ថ្នាក់ជាឥណទាន និងគណនីត្រូវទទួលនៅក្រោមស្តង់ដារពីមុន ត្រូវបានចាត់ថ្នាក់តាមរំលស់ថ្លៃដើម ។ សម្រាប់និយ័តកម្មសូមមើលកំណត់សម្គាល់ ក(ii) និង ក(iii) ខាងក្រោម ។

(គ) នៅក្រោមស្តង់ដារពីមុន បំណុលហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់តាមថ្លៃដើម ឥឡូវត្រូវបានចាត់ថ្នាក់តាមរំលស់ថ្លៃដើមជំនួសវិញ ។ សូមមើលនិយ័តកម្ម ក(iii) ខាងក្រោម ។

(ii). ឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ស.រ.ហ.អ.ក 9 ជំនួសឲ្យគំរូស្តង់ដារពីមុន "ការខាតបង់ដែលបានកើតឡើង" ជាមួយនឹងគំរូ "ការរំពឹងទុកឥណទានខាតបង់ (ECL)" ។ គំរូនៃឱនភាពនៃតម្លៃថ្មី អនុវត្តចំពោះតែទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។

ការអនុវត្តនូវតម្រូវការឱនភាពនៃតម្លៃតាម ស.រ.ហ.អ.ក 9 នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 បង្កើតឲ្យមានសំវិធានធនសម្រាប់ឱនភាពនៃតម្លៃដូចខាងក្រោម៖

	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដុល្លារអាមេរិក	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក
សំវិធានធនខាតបង់ ក្រោមស្តង់ដារពីមុន	4,769,307	6,304,442
ការបង្វិលនៃឱនភាពលើតម្លៃទទួលស្គាល់លើ:		
ឥណទាន និងបុរេប្រទានឱ្យអតិថិជន	(1,646,827)	(1,535,087)
ការវាស់វែងនៃឱនភាពដែលត្រូវបានទទួលស្គាល់ ក្រោម ស.រ.ទ.ហ.អ.ក	486,744	571,059
សំវិធានធនខាតបង់ ក្រោម ស.រ.ទ.ហ.អ.ក	3,609,225	5,340,414
សំវិធានធនខាតបង់ក្រោម ស.រ.ទ.ហ.អ.ក (ពាន់រៀល-កំណត់សម្គាល់ 5)	14,570,441	21,559,251

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រដែលធនាគារប្រើសម្រាប់វាស់វែង ឱនភាពនៃតម្លៃលើសំវិធានធន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 32គ (vii) និង 30ខ។

(iii). ការប្រាក់

នៅក្រោមស្តង់ដារពីមុន កម្រៃដែលជាផ្នែកមួយនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ មិនត្រូវបានបញ្ចូលជាអត្រាការប្រាក់ប្រសិទ្ធភាពនោះទេ ហើយត្រូវបានទទួលស្គាល់ថាជា ចំណូលនៅពេលប្រតិបត្តិការកើតឡើង ។ បន្ថែមពីនេះ ការទទួលស្គាល់ចំណូលការប្រាក់ ត្រូវបានផ្អាកនៅពេលដែលឥណទានមិនដំណើរការ ។

នៅក្រោម ស.រ.ទ.ហ.អ.ក ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") ថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ ។ ការទទួលស្គាល់ចំណូលការប្រាក់មិនត្រូវបានផ្អាកនៅពេលដែលឥណទានមិនដំណើរការនោះទេ ។

ផលប៉ះពាល់ដែលកើតឡើងពីការផ្លាស់ប្តូរត្រូវបានសង្ខេបដូចខាងក្រោម៖

	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដុល្លារអាមេរិក	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ		
ការថយចុះនៃឥណទាន និងបុរេប្រទាន	(391,612)	(499,633)
ពន្ធដែលពាក់ព័ន្ធ	78,322	99,927
និយ័តភាពលើប្រាក់ចំណេញរក្សាទុក	(313,290)	(399,706)
និយ័តភាពលើប្រាក់ចំណេញរក្សាទុក (ពាន់រៀល-កំណត់សម្គាល់5)	(1,264,752)	(1,606,019)

ធនាគារ អភិវឌ្ឍន៍ជនបទ

(បច្ចុប្បន្នត្រូវបានគេស្គាល់ថា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម)

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

33. ព័ត៌មានប្រៀបធៀប (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iii). ការប្រាក់ (ត)

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ	2018 ដុល្លារអាមេរិក
ការកើនឡើងនៃចំណូលការប្រាក់	277,354
ការថយចុះនៃចំណូលផ្សេងៗ	(1,054,800)
និយ័តភាពលើប្រាក់ចំណេញមុនបង់ពន្ធ	(777,446)
និយ័តភាពលើប្រាក់ចំណេញមុនបង់ពន្ធ (ពាន់រៀល - កំណត់សម្គាល់ 5)	(3,144,769)

(iv). ផលប៉ះពាល់នៃអន្តរកាលលើមូលធន

តារាងខាងក្រោមសង្ខេបអំពីផលប៉ះពាល់ក្រោយដកពន្ធនៃអន្តរកាលទៅ ស.រ.ហ.អ.ក 9 លើប្រាក់ចំណេញរក្សាទុក នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

	ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក 9 នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ចំណេញរក្សាទុក		
សមតុល្យចុងគ្រាក្រោមស្តង់ដារពីមុន (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017)	7,161,349	28,910,366
ផលប៉ះពាល់លើការស្តារឡើងវិញ (កំណត់សម្គាល់ 33គ)	(11,220,150)	(45,295,746)
ការវាស់វែងឡើងវិញតាមរំលស់ថ្លៃដើមក្រោម ស.រ.ហ.អ.ក 9	(582,406)	(2,351,173)
ការទទួលស្គាល់ការរំពឹងទុកឥណទានខាតបង់ក្រោម ស.រ.ហ.អ.ក 9	1,160,083	4,683,255
ពន្ធដែលពាក់ព័ន្ធ	(1,904,939)	(7,690,238)
សមតុល្យដើមគ្រាក្រោម ស.រ.ហ.អ.ក 9 (ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018)	(5,386,063)	(21,743,536)

33. ព័ត៌មានប្រៀបធៀប (ត)

ឃ. ពន្ធលើប្រាក់ចំណេញ

ការផ្លាស់ប្តូរខាងលើដែលបាន(ថយចុះ)/កើនឡើង លើពន្ធពន្យារជាទ្រព្យសកម្មមានដូចខាងក្រោម៖

	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដុល្លារអាមេរិក	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក
សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន	2,009,647	1,490,107
ចំណូលកម្រៃនិងជើងសាសម្រាប់កម្ចី	(78,322)	(99,927)
ការថយចុះ នៃពន្ធពន្យារជាបំណុល	1,931,325	1,390,180
ការថយចុះ នៃពន្ធពន្យារជាបំណុល (ពាន់រៀល - កំណត់សម្គាល់ 5)	7,796,759	5,612,157

ការកែតម្រូវសំខាន់ទៅលើរបាយការណ៍លំហូរទឹកប្រាក់សំរាប់ឆ្នាំ 2018

របាយការណ៍លំហូរសាច់ប្រាក់ត្រូវបានបង្ហាញក្រោមស្តង់ដារស.រ.ហ.អ.ក ដែលមានភាពប្រហាក់ប្រហែលទៅនឹងរបាយការណ៍លំហូរសាច់ប្រាក់ត្រូវបានបង្ហាញក្រោមស្តង់ដារចាស់ ។

34. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

វីរុសកូរ៉ូណា និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក

ការរំពឹងលើការបាត់បង់ឥណទាននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2019 ត្រូវបានប៉ាន់ស្មានដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ចដែលបានព្យាករណ៍នាកាលបរិច្ឆេទនោះ ។ នាកាលបរិច្ឆេទបន្ទាប់ មានការផ្ទុះឡើងនៃវីរុសកូរ៉ូណាបានរីករាលដាលនៅប្រទេសចិនដីគោក កម្ពុជា និងបណ្តាប្រទេសដទៃទៀត ដែលបង្កឲ្យមានការរំខានដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច ។ ផលប៉ះពាល់លើកំណើនផលិតផលក្នុងស្រុកដុល (GDP) និងសូចនាករសំខាន់ផ្សេងៗ នឹងត្រូវពិចារណា ក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភាពដែលអាចទៅរួចនៃការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ដែលនឹងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការរំពឹងទុកលើការខាតបង់ឥណទានក្រោម ស.រ.ហ.អ.ក 9 ក្នុងឆ្នាំ 2020 ។